**សេចក្តីសិក្សា៖** មេរៀននេះមានរយៈពេលប្រហែល ៥ ម៉ោង ដើម្បីសិក្សា។ ប្រសិនបើអ្នកមិនមានពេល អ្នកអាចមានភាពងាយស្រួលក្នុងការសិក្សាបន្ទាប់ពីធ្វើការស្តាប់សម្លេងវគ្គទីបី ។

---

# មេរៀនទី ២ សិទ្ធិអ្នកនិពន្ធ

## គោលបំណង

បន្ទាប់ពីបញ្ចប់ការសិក្សាមេរៀននេះអ្នកគួរតែអាច

១. ឱ្យអត្ថន័យសិទ្ធិអ្នកនិពន្ធ និងផ្តល់ ឧទាហរណ៍ប្រភេទនៃស្នាដៃ ដែលគ្របដណ្តប់ដោយសិទ្ធិអ្នកនិពន្ធ។

២. ពន្យល់ អំពីសិទ្ធិចំនួន ២៥០ ពាក្យ ដែលត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ។ សិទ្ធិនៃការចម្លង សិទ្ធិនៃការសម្តែង ការបកប្រែ និងការយកលំនាំតាម។

៣. ពិពណ៌នាអំពីការដាក់កំហិតចំនួន ២៥០ពាក្យ ដែលប្រហែលមាននៅក្នុងសិទ្ធិដែលគ្របដណ្តប់ដោយគោលបំណងទី២។

៤. ថ្លែងអំពីរយៈពេលទូទៅរបស់សិទ្ធិអ្នកនិពន្ធ ដែលត្រូវបានផ្តល់ក្នុងអនុសញ្ញាទីក្រុងប៊ែន ក្នុង សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។

៥. ពន្យល់ ភាពជាម្ចាស់នៃសិទ្ធិអ្នកនិពន្ធ អាចត្រូវបានទទួល និងផ្ទេរយ៉ាងដូចម្តេច។

៦. រាយបញ្ជី វិធានការចំនួន ០៥ ដែលអាចត្រូវបានធ្លាប់ប្រើសិទ្ធិចាប់បង្ខំ។

៧. ផ្តល់ករណីសិក្សាមួយដែលកំពុងតែពាក់ព័ន្ធបញ្ហាសិទ្ធិអ្នកនិពន្ធ ទីមួយកំណត់អំពីបញ្ហាទាំងនោះ បន្ទាប់មកបង្ហាញ ផ្នែកខ្លះៗដែលត្រូវបានអនុវត្តនៃទាក់ទងសន្ធិសញ្ញាផ្សេងៗ ដែលនិយាយពីបញ្ហាដែលបានកំណត់។

©WIPO/OMPI

## សេចក្ដីផ្ដើម

មេរៀនសិទ្ធិអ្នកនិពន្ធនេះ ពន្យល់អំពីប្រភេទផ្សេងៗ (ស្នាដៃ) ដែលត្រូវបានការពារក្រោមចំណងជើង សិទ្ធិអ្នកនិពន្ធ សិទ្ធិដែលម្ចាស់សិទ្ធិអ្នកនិពន្ធមាន និងរបៀប ដែលត្រូវបានប្រើប្រាស់សិទ្ធិទាំងនោះសម្រាប់គុណសម្បត្តិពាណិជ្ជកម្ម។ ច្បាប់ជាច្រើនដែលពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធគឺស្រដៀងទៅនឹងប្រទេសទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងៗ។ ប៉ុន្តែ សម្រាប់ចម្លើយច្បាស់លាស់មួយនៃសំនួរសិទ្ធិអ្នកនិពន្ធផ្សេងៗ ច្បាប់(សិទ្ធិអ្នកនិពន្ធ)នៃប្រទេសរបស់អ្នកគួរត្រូវបានពិគ្រោះ។ អ្នកនឹងឃើញព្រមទាំងស្តាប់អំពីឯកសារយោងពាក់ព័ន្ធទៅនឹងអនុសញ្ញាទីក្រុងប៉ែន និងកិច្ចព្រមព្រៀងTRIPS ក្នុងមេរៀននេះ ហើយអនុសញ្ញានិងកិច្ចព្រមព្រៀងនោះនឹងត្រូវបានពន្យល់នៅចុងបញ្ចប់នៃមេរៀននេះ។សម្រាប់ពេលនេះគ្រាន់តែដឹងថា អនុសញ្ញា និងកិច្ចព្រមព្រៀងនោះ គឺជាកិច្ចព្រមព្រៀងអន្តរជាតិពីរទាក់ទងទៅនឹងវិស័យសិទ្ធិអ្នកនិពន្ធ។

ហើយត្រូវបានពន្យល់ផងដែរពី មធ្យោបាយដោះស្រាយផ្សេងៗដែល ម្ចាស់សិទ្ធិអ្នកនិពន្ធប្រហែលជំទាស់រាល់ការបំពានផ្សេងៗលើសិទ្ធិរបស់ពួកគេ។ ក្រៅពីនេះ មធ្យោបាយដោះស្រាយទាំងនេះ គឺអាចប្រើប្រាស់បានក្នុងប្រទេសជាច្រើនប៉ុន្តែអ្នកគួរតែពិគ្រោះជាមួយច្បាប់ជាតិរបស់អ្នក ដើម្បីច្បាស់អំពីស្ថានភាពក្នុងប្រទេសរបស់អ្នក។

## តើអ្វីខ្លះ(ស្នាដៃ)ដែលគ្របដណ្តប់ដោយសិទ្ធិអ្នកនិពន្ធ?

ដូចជាគ្រប់វិស័យនៃកម្មសិទ្ធិបញ្ញាផងដែរ សិទ្ធិអ្នកនិពន្ធគឺពាក់ព័ន្ធជាមួយនឹងការពារស្នាដៃនៃបញ្ញាមនុស្ស។ កម្មសិទ្ធិនៃសិទ្ធិអ្នកនិពន្ធគឺការពារស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈផ្សេងៗ។ ស្នាដៃទាំងនោះ រួមទាំងអក្សរ តន្ត្រី និងស្នាដៃផ្សេងៗ នៃវិចិត្រសិល្បៈ ដូចជាគំនូរលាបពណ៌ រូបចម្លាក់(សិល្បៈជាងចម្លាក់) និងស្នាដៃដែលផ្អែកទៅលើបច្ចេកវិទ្យា ដូចជាកម្មវិធីកំព្យូទ័រ និងប្រព័ន្ធទិន្ន័យអេឡិចត្រូនិចផ្សេងៗ។

សម្គាល់ថាការពារស្នាដៃសិទ្ធិអ្នកនិពន្ធ គឺជាការសម្តែងពីគំនិត និងមិនមែនគ្រាន់តែជាគំនិតនោះទេ។ ដូច្នេះប្រសិនបើអ្នកស្រមើលស្រមៃពីប្លង់ណាមួយនៃដំណើររឿង គឺមិនត្រូវបានការពារនោះទេ។ ឧទាហរណ៍ ពីប្លង់មួយនៃដំណើររឿងនៃរឿងរ៉ាវមួយអំពីបុរស និងស្ត្រីវ័យក្មេងកំពុងធ្លាក់ក្នុងអន្លង់ស្នេហ៍ថ្វីបើគ្រួសារ និងវណ្ណៈជាឧបសគ្គដ៏ដោយ នឹងមិនត្រូវបានការពារនោះទេ។ អ្នកនិពន្ធផ្សេងៗប្រហែលជានិពន្ធរឿងជាច្រើនដោយផ្តោតទៅនឹងដំណើររឿងប្រហាក់ប្រហែលគ្នានេះ។ ប៉ុន្តែនៅពេលអ្នកសម្តែងវាជារឿងខ្លី ឬរឿងរ៉ាវខ្លីមួយដោយការនិយាយ ឬសម្តែង ដោយរបៀបសម្តែងដំណើររឿងមួយក្នុងរឿងរ៉ាវនោះនឹងត្រូវបានការពារ។ ហេតុនេះសម្រាប់ជាឧទាហរណ៍ការសម្តែងរបស់ សេកស្ពៀ(Shakespear) ក្នុងរឿងរូមីអូ និងជូលាត (Romeo and Juliet) នឹងត្រូវ

©WIPO/OMPI

បានពិចារណាជារបៀបសម្តែងប្រកបដោយការច្នៃប្រឌិតនៃដំណើររឿងនោះ។ យ៉ាងណាក៏ដោយ អ្នកនិពន្ធដទៃជាច្រើនប្រហែលជានិពន្ធរឿងថ្មីៗ ដោយផ្តោតទៅនឹងដំណើររឿងប្រហាក់ប្រហែលគ្នានេះ ។

អនុសញ្ញាទីក្រុងប៉ែន (ឆ្នាំ១៨៨៦) ជាអនុសញ្ញាអន្តរជាតិចំណាស់មួយដែលគ្រប់គ្រងសិទ្ធិអ្នកនិពន្ធ ចែងដូចតទៅនៅក្នុងមាត្រា ២

ពាក្យថា "ស្នាដៃអក្សរសាស្ត្រនិងសិល្បៈ" រួមបញ្ចូលគ្រប់ ផលិតផលនៃវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈ ទោះបីការ សម្តែងស្នាដៃ មានរបៀបឬទម្រង់ណាក៏ដោយ ដូចជា សៀវភៅ កូនសៀវភៅផ្សព្វផ្សាយព័ត៌មាន និងការនិពន្ធផ្សេងទៀត អត្ថបទ បាឋកថា សុន្ទរកថា ធម្មទេសនា និងស្នាដៃផ្សេងទៀតដែលមាន ប្រភេទដូចគ្នា ស្នាដៃនាដកម្ម ឬនាដកម្មតូរ្យតន្ត្រី ស្នាដៃរបាំ និងការកំសាន្ត តាមរយៈការសម្តែងកាយវិការ ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ស្នាដៃភាពយន្ត និងស្នាដៃទាំងឡាយដែលបង្ហាញ ដំណើរការដូចគ្នានឹងការថតភាពយន្ត ស្នាដៃជាផ្ទាំងគំនូរ គំនូរផាត់ ពណ៌ ស្ថាបត្យកម្ម រូបចម្លាក់ ផ្ទាំងចម្លាក់ ស្នាដៃពុម្ពថ្មចម្លាក់ ស្នាដៃ ថតរូប និងស្នាដៃទាំងឡាយបង្ហាញដំណើរការដូចគ្នានឹងការថតរូប ស្នាដៃសិល្បៈអនុវត្ត រូបភាពពន្យល់ ផែនទី ប្លង់ គំនូសវាសនិង ស្នាដៃ ទម្រង់បីខ្នាតទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ស្ថាបត្យកម្ម ឬវិទ្យាសាស្ត្រ។ (......) ការបកប្រែ ការយកលំនាំតាម ការសម្រួលតន្ត្រី និងការកែ ប្រែផ្សេងទៀតនៃស្នាដៃអក្សរសាស្ត្រឬសិល្បៈ ត្រូវការពារដូចស្នាដៃ ដើម ដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធស្នាដៃដើម (......) ការចងក្រងស្នាដៃអក្សរសាស្ត្រឬសិល្បៈ ដូចជាឯកសារ សមោធាន និងកម្រងស្នាដៃដោយមូលហេតុនៃការជ្រើសរើស និង រៀបចំជាមាតិកាដែលជាការបង្កើតផ្នែកបញ្ញា ត្រូវការពារបែបនោះ ដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធស្នាដៃនីមួយៗ ដែលជាផ្នែកនៃ ការចងក្រងនេះឡើយ។

មិនតម្រូវឱ្យស្នាដៃអក្សរសាស្ត្រ ឬស្នាដៃសិល្បៈគួរជាស្នាដៃល្អ ឬ សិល្បៈមានតម្លៃនោះទេ។ យ៉ាងណាក៏ដោយស្នាដៃគួរតែជាស្នាដៃដើម។ តម្រូវការនេះ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ហើយជាទូទៅវាត្រូវបានកំណត់ដោយច្បាប់។ ក្នុងចំណោមល័ក្ខខ័ណ្ឌទូទៅមួយអាចនឹងនិយាយថា ក្នុងប្រទេសដែលប្រកាន់យកទំលាប់ច្បាប់ទូទៅ(Common Law) គឺមានតម្រូវការតិចតួចណាស់ ក្រៅពីនោះស្នាដៃមិនត្រូវបានថតចម្លងពីស្នាដៃមួយផ្សេងទៀតនោះទេ ដែលអ្នកនិពន្ធគួរតែត្រូវបានបង្ហាញនូវចំនួនអប្បបរមាពីជំនាញ ពលកម្ម ការវិនិច្ឆ័យក្នុងការបង្កើតស្នាដៃ។ ក្នុងបណ្តាប្រទេសប្រកាន់យកទំលាប់ច្បាប់រដ្ឋប្បវេណី តម្រូវការគឺជាញឹកញាប់មានភាពខ្ពស់បំផុត ឧទាហរណ៍ថា ស្នាដៃត្រូវផ្តល់ត្រា ជាបុគ្គលិកលក្ខណៈអ្នកនិពន្ធ។ ការខំប្រឹងច្នៃប្រឌិតមួយនឹងត្រូវបានតម្រូវពីអ្នកនិពន្ធដែលប្រហែលលើសពីជំនាញ ពលកម្ម និងលក្ខណៈវិនិច្ឆ័យ។

©WIPO/OMPI

តើស្នាដៃទាំងឡាយ ដែលអាចត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងប៊ែនដាក់កំណត់មានលក្ខខណ្ឌទៅនឹងតារាងកំណត់ក្នុងមាត្រា២ឬទេ?

ស្នាដៃគួរត្រូវកើតឡើងពីគំនិតដែលស្នាដៃទាំងនោះ គឺងាយត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងប៊ែនដែលមិនត្រូវបានដាក់កំណត់មានលក្ខខ័ណ្ឌគឺដូច ពីឧទាហរណ៍បានស្រង់ចេញខាងលើ។ ដូច្នេះបញ្ជីមួយគឺមិនត្រូវទូលំទូលាយ។ អ្នកនឹងបានសង្កេតមើលថាអនុសញ្ញាទីក្រុងប៊ែនបញ្ជាក់ថា "ការសម្តែងស្នាដៃ អក្សរសាស្រ្ត និងសិល្បៈ នឹងរួមទាំងផលិតកម្មក្នុងវិស័យ អក្សរសាស្រ្ត វិទ្យាសាស្រ្ត និងសិល្បៈ អ្វីក៏ដោយប្រហែលជា វិធី ឬ ទម្រង់ នៃការសម្តែងរបស់វាដូច្នេះ....." ការសម្តែង "ដូច្នេះ" ចំបាច់ទ្វាដើម្បីឈានទៅដល់ការច្នៃប្រឌិតថ្មីក្រៅពីការច្នៃប្រឌិតដែលបង្ហាញក្នុងបញ្ជី។ ឧទាហរណ៍ ការសម្រេចរបស់តុលាការក្នុងប្រទេសផ្សេងៗបានការពារសម្ភារៈដូចជា

-សំបុត្រឯកជន

-ការណែនាំពីការលែងលះគ្នា

-ការកាត់សក់

-ការលំអរផ្កាលើស្ពានមួយ

-ការបង្ហាញ "Son-et-lumiere"

-ក្រដាសប្រឡងផ្សេងៗ

©WIPO/OMPI

## តើអ្វីទៅជាស្នាដៃបន្ត?

លក្ខណៈសំខាន់ដទៃផ្សេងៗទៀតនៃមាត្រា២ នៃអនុសញ្ញាទីក្រុងប៊ែន គឺអនុសញ្ញាការពារ "ស្នាដៃបន្ត"។ស្នាដៃបន្តទាំងនោះកើតចេញពីស្នាដៃដទៃដែលមានប្រភពរួចហើយឧទាហរណ៍នៃស្នាដៃបន្តរួមមានៈ

- ការបកប្រែស្នាដៃផ្សេងៗទៅជាភាសាផ្សេងទៀត

-ការយកលំនាំតាមស្នាដៃផ្សេងៗ ដូចជាការបង្កើតឆាកភាពយន្តដែលបានផ្តោតលើប្រលោមលោកមួយ

-ការរៀបចំបទភ្លេង ដូចជាជំនាន់វង់ភ្លេងមួយនៃការតែងបទភ្លេងដំបូងគេដែលតែងដោយព្យាណូ

-ការកែប្រែស្នាដៃដទៃផ្សេងៗ ឧទាហរណ៍ ការសង្ខេបប្រលោមលោកមួយ

-ការចងក្រងស្នាដៃអក្សរសាស្ត្រនិងសិល្បៈដូចជាសព្វវចនាធិប្បាយ កំរងកំណាព្យផ្សេងៗ

។ក្នុងករណីបែបនេះភាពដើមបិតនៅលើការជ្រើសរើសនិងរៀបចំស្នាដៃទាំងនោះ ។ អ្នកត្រូវចងចាំថា មុននឹងចាប់ផ្តើមបង្កើតស្នាដៃបន្ត អ្នកត្រូវតែគោរពសិទ្ធិរបស់អ្នកនិពន្ធនៃស្នាដៃដំបូង។ ឧទាហរណ៍ អ្នកនិពន្ធម្នាក់ដែលចង់បកប្រែប្រលោមលោកមួយទៅជាភាសាបរទេសមួយគួរស្វែងរកការអនុញ្ញាតត្រឹមត្រូវពីអ្នកនិពន្ធប្រលោមលោកដែលនឹងត្រូវយកមកបកប្រែ។ ការធ្វើការបកប្រែដែលមិនមានការអនុញ្ញាតត្រឹមត្រូវ អ្នកបកប្រែ នឹងមានហានិភ័យត្រូវគេប្តឹងពីបទរំលោភបំពានសិទ្ធិអ្នកនិពន្ធ។

©WIPO/OMPI

## វគ្គសម្លេងទី ១: តើប្រភេទស្នាដៃអ្វីខ្លះអាចត្រូវបានការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធ?

សិទ្ធិអ្នកនិពន្ធការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ដែលមានចែងក្នុងចំណងជើងរបស់អនុសញ្ញាទីក្រុងប៊ែន។ គំនិតពីរត្រូវបានលើកឡើងក្នុងន័យទូលាយ ។ ពាក្យសិល្បៈ មិនមែនមានន័យត្រឹមតែជាប្រលោមលោក កំណាព្យ ឬរឿងរ៉ាវខ្លីៗនោះទេ វាអាចគ្របដណ្ដប់លើសេចក្តីណែនាំពីការថែទាំយានយន្ត ឬការនិពន្ធដែល មិនអាចយល់បានដោយមនុស្សភាគច្រើន ដូចជាកម្មវិធីកុំព្យូទ័រផ្សេងៗ។ ធាតុសំខាន់នៃពាក្យនេះ គឺ ពាក្យ “ស្នាដៃ”។ អ្វីដែលយើងមានន័យនៅទីនេះគឺ ការសម្តែងរបស់មនុស្ស គឺជាកត្តាសម្រេចចិត្ត។ ដូច្នេះប្រសិនបើខ្ញុំមានគំនិតនៃគំនូរលាបពណ៌ “ព្រះអាទិត្យលើសមុទ្រ” អ្នកណាម្នាក់ផ្សេងទៀតក៏អាចប្រើគំនិតដូចគ្នានេះដែរ មិនត្រូវបានការពារនោះទេ។ ប៉ុន្តែ នៅពេលដែលខ្ញុំគំនូរលាបពណ៌របស់ខ្ញុំអំពី“ព្រះអាទិត្យលើសមុទ្រ” គំនូរលាបពណ៌នោះគឺជាការសម្តែង និងត្រូវបានការពារ។

©WIPO/OMPI

## សំនួរវាយតម្លៃខ្លួនឯង(SAQ)

(SAQ) 1: តើស្លាដែកម្មសិទ្ធិបញ្ញាសំខាន់ដែលបាននិយាយដោយវាគ្មិន មិនរួមចញ្ចូលក្នុងបញ្ជី “ស្លាដែអក្សរសាស្រ្ត និងសិល្បៈ” នៃអនុសញ្ញាទីក្រុងប៉ែនមានអ្វីខ្លះ។

សរសេរចម្លើយរបស់អ្នកទីនេះ
ចុចទីនេះសម្រាប់ចម្លើយ

©WIPO/OMPI

(SAQ) 1 ចម្លើយ:

ការលើកលែងសំខាន់បំផុតពីបញ្ជីដែលបាននិយាយក្នុងវគ្គសម្លេង គឺជាកម្មវិធីកុំព្យូទ័រផ្សេងៗ។ ទាំងនេះគឺជាផលនៃការច្នៃប្រឌិតដោយបញ្ញា ហើយត្រូវបានចាត់ទុកជាស្នា។ សខាន់គួរកត់សម្គាល់ថាបញ្ជីក្នុងអនុសញ្ញាទីក្រុងប៊ែន គឺមិនមែនជាបញ្ជីមានលក្ខណៈពេញលេញនិងកម្រិតនោះទេ។ គ្រាន់តែជាការបង្ហាញពីលក្ខណៈនៃស្នាដៃអក្សរសាស្រ្តនិងសិល្បៈតែប៉ុណ្ណោះ។ ប្រភេទស្នាដៃថ្មីៗទៀតដែលមិនបានកំណត់ក្នុងបញ្ជីក្នុងមាត្រា ២ នៃអនុសញ្ញាទីក្រុងប៊ែន ប៉ុន្តែត្រូវបានបញ្ចូលក្នុងសញ្ញាណនៃនៃការច្នៃប្រឌិតមួយ “ក្នុងវិស័យអក្សរសាស្រ្ត វិទ្យាសាស្រ្ត និងសិល្បៈ” គឺជាផលិតផលនៃប្រព័ន្ធផ្សព្វផ្សាយចំរុះពហុព័ត៌មាន។ ក្នុងកំឡុងពេលដែលមិនមាននិយមន័យស្របច្បាប់ដែលអាចទទួលយកបាន មានការព្រមព្រៀងជាឯកចន្ទមួយថាការរួមបញ្ចូលគ្នាដើមនៃសម្លេង អត្ថបទ និងរូបភាពក្នុងទម្រង់ឌីជីថលដែលអាចដំណើរការបានដោយកម្មវិធីកុំព្យូទ័រ តំណាងអោយភាពជាអ្នកនិពន្ធ គឺគ្រប់គ្រាន់ដើម្បីការពារជាស្នាដៃផលិតផលនៃប្រព័ន្ធផ្សព្វផ្សាយចំរុះក្រោមឆ័ត្រសិទ្ធិអ្នកនិពន្ធ។

©WIPO/OMPI

## តើសិទ្ធិអ្វីខ្លះដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ?

ក្នុងអារម្ភកថាក្នុងមេរៀននេះ បានពន្យល់ថាលក្ខណៈសំខាន់បំផុតនៃទ្រព្យគឺថាម្ចាស់សិទ្ធិ អាចប្រើប្រាស់សិទ្ធិផ្តាច់មុនបាន ឧទាហរណ៍ ដូចជាសិទ្ធិប្រើប្រាស់តាមដែលអ្នកចង់បាន ហើយ គ្មាននរណាម្នាក់អាចប្រើប្រាស់ត្រឹមត្រូវតាមច្បាប់ដោយគ្មានការអនុញ្ញាតពីម្ចាស់នោះទេ។ ឃ្លា “សិទ្ធិប្រើប្រាស់តាមដែលអ្នកចង់បាន មិនមែនមានន័យថា ពួកគេអាចប្រើប្រាស់ ដោយមិនគិតពី សិទ្ធិដែលទទួលស្គាស់ដោយស្របច្បាប់ និងផលប្រយោជន៍របស់សមាជិកដ៏ទៃទៀតនៃសង្គម នោះឡើយ។ ឧទាហរណ៍ ម្ចាស់ឡានមួយអាចនឹងប្រើប្រាស់វា “តាមតែអ្នកចង់” ប៉ុន្តែនេះមិន មែនមានន័យថានាងអាចបើកបរឡានរបស់នាងដោលមិនប្រយ័ត្នប្រយ៉ែង និងបង្ករគ្រោះថ្នាដល់ អ្នកដ៏ទៃផ្សេងទៀត មិនមានន័យថា នាងនឹងអាចមិនយកចិត្តទុកដាក់ចំពោះបទបញ្ជាចរាចរនោះ ទេ។ សិទ្ធិអ្នកនិពន្ធគឺជាមែកធាងនៃកម្មសិទ្ធិបញ្ញា។ ម្ចាស់សិទ្ធិអ្នកនិពន្ធស្នាដៃដែលបានការពារ អាចនឹងប្រើប្រាស់ស្នាដៃដូចដែលខ្លួនចង់បាន និងអាចនឹងរារាំងអ្នកដ៏ទៃផ្សេងទៀតពីការប្រើ ប្រាស់វាដោយគ្មានការអនុញ្ញាត។ ដូច្នេះសិទ្ធិដែលអនុញ្ញាតក្រោមច្បាប់ជាតិ ចំពោះម្ចាស់សិទ្ធិ អ្នកនិពន្ធក្នុងស្នាដៃដែលបានការពារមួយគឺធម្មតាជា”សិទ្ធិផ្តាច់មុខ”: ប្រើប្រាស់ស្នាដៃ ឬអនុញ្ញាត អោយអ្នកដ៏ទៀតប្រើប្រាស់ស្នាដៃ ស្របតាម សិទ្ធិដែលទទួលស្គាល់ដោយស្របច្បាប់ និងផល ប្រយោជន៍របស់អ្នកដ៏ទៃទៀត។

មានសិទ្ធិពីរប្រភេទស្ថិតក្រោមសិទ្ធិអ្នកនិពន្ធ: សិទ្ធិសេដ្ឋកិច្ច(សិទ្ធិបេតិកភ័ណ្ឌ) ដែល អនុញ្ញាតឱ្យម្ចាស់សិទ្ធិទាញយករង្វាន់ហិរញ្ញវត្ថុពីការប្រើប្រាស់ស្នាដៃរបស់ខ្លួនដោយអ្នកដ៏ទៃ និង សិទ្ធិសីលធម៌ ដែលអនុញ្ញាតអោយអ្នកនិពន្ធចាត់វិធានការដើម្បីរក្សាទំនាក់ទំនងផ្ទាល់ខ្លួន រវាង ខ្លួនគាត់ផ្ទាល់និងស្នាដៃ។ ឥឡូវសូមស្តាប់វគ្គសម្លេង និងសាកល្បងញែកសិទ្ធិសេដ្ឋកិច្ចផ្សេងៗ ដែលបានពិពណ៌នា។

©WIPO/OMPI

សម្លេងវគ្គ ២: តើសិទ្ធិអ្វីខ្លះដែលម្ចាស់សិទ្ធិអ្នកនិពន្ធមាន?

ម្ចាស់សិទ្ធិអ្នកនិពន្ធមានបណ្តុំនៃសិទ្ធិផ្សេងៗ ដែលគ្រប់គ្រងដោយផ្នែកដោយអនុសញ្ញាទីក្រុងប៊ែន ដែលជាសិទ្ធិអប្បបរមា និងដោយផ្នែកដោយច្បាប់ជាតិ ដែលជាទូទៅមានសិទ្ធិវែងជាង។ ជាប្រពៃណី និងប្រវត្តិសាស្ត្រ សិទ្ធិផលិតឡើងវិញ គឺជាគន្លឹះដែលបានឆ្លុះបញ្ចាំង ក្នុងពាក្យសិទ្ធិអ្នកនិពន្ធ។ សិទ្ធិផលិតឡើងវិញគ្របដណ្តប់លើការបោះពុម្ពសៀវភៅ និងការថតចម្លងផងដែរ។ ប៉ុន្តែសិទ្ធិផលិតឡើងវិញក៏គ្របដណ្តប់វិធីសាស្ត្រទំនើបជាច្រើននៃការផលិតឡើងវិញដូចជា ការថតចម្លងជាខ្សែអាត់ និងការថតចម្លងនៃការថតចម្លងខ្សែអាត់។ សិទ្ធិផលិតឡើងវិញគ្របដណ្តប់ការរក្សាទុកស្នាដៃក្នុងអង្គចងចាំកុំព្យូទ័ ការថតចម្លងនៃកម្មវិធីកុំព្យូទ័រ ក្នុងឌីសស្គិត ស៊ីឌីរ៉ូម ស៊ីឌីរីតដៃបលរ៉ូម ជាដើម។

សិទ្ធិដទៃទៀតមានដែលមានប្រវត្តិសាស្ត្រមួយដ៏វែងគឺជាសិទ្ធិសម្តែង។ អ្នកសម្តែងស្នាដៃនៅពេលមានបទភ្លេងមួយ ឬពេលអ្នកដើរតួលើឆាក ហើយរយៈកាលជាច្រើនឆ្នាំកន្លងមក សិទ្ធិនេះ បង្កើតសិទ្ធិផ្សេងទៀតជាច្រើន ដូចជាសិទ្ធិទូរផ្សាយ និងសិទ្ធិផ្សព្វផ្សាយជាសាធារណៈ។ សិទ្ធិផ្សព្វផ្សាយជាសាធារណៈ ពេលខ្លះត្រូវបានកំណត់ខុសៗគ្នាក្នុងច្បាប់ជាតិផ្សេងៗ ការផ្សាយតាមទូរផ្សាយ អាចនឹងបង្កើតជាផ្នែកមួយនៃការផ្សាព្វផ្សាយជា សាធារណៈ ឬសិទ្ធិទាំងនេះ បានភ្ជាប់នឹងគំនិតដូចគ្នា ប៉ុន្តែត្រូវបានគ្របដណ្តប់ប្រភេទទាំងអស់នៃ ការផ្សព្វផ្សាយ ដែលការផ្សាយតាមទូរផ្សាយជាមួយ ការផ្សព្វផ្សាយតាមខ្សែ និងតាមអ៊ិនធឺណេត ជាប្រភេទមួយផ្សេងទៀងនៃការផ្សព្វផ្សាយ។

©WIPO/OMPI

សំនួរវាយតម្លៃខ្លួនឯង(SAQ)

(SAQ) 2: តើសិទ្ធិទាំងពីរប្រភេទដែលបានបញ្ជាក់ក្នុងសម្លេងជាអ្វី? ផ្តល់ឧទាហរណ៍សម្រាប់សិទ្ធិនីមួយៗ

សរសេរចម្លើយរបស់អ្នកទីនេះ

ចុចទីនេះសម្រាប់ចម្លើយ

©WIPO/OMPI

(SAQ) 2 ចម្លើយ:

សិទ្ធិពីរដែលបានបញ្ជាក់នោះរួមមាន:

សិទ្ធិផលិតឡើងវិញ ឧទាហរណ៍នៃសិទ្ធិនេះគឺជាសិទ្ធិអនុញ្ញាតឱ្យថតចម្លង បោះពុម្ព ឬថតចម្លងជាការសែត

សិទ្ធិទាក់ទងនឹងការសម្តែង។ល។ ឧទាហរណ៍នេះគឺជាសិទ្ធិសម្តែងស្នាដៃ ដូចជាចម្រៀងមួយបទ និងសិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណនិងផ្សព្វផ្សាយតាមទូរផ្សាយ។

ក្រុមសិទ្ធិដ៏សំខាន់ដទៃមួយទៀត ដែលមិនបានបញ្ជាក់ក្នុងវគ្គសម្លេងគឺសិទ្ធិទាក់ទងនឹងការបកប្រែ និងការយកលំនាំតាម។ គ្រប់សិទ្ធិទាំងនេះនឹងពន្យល់ក្នុងផ្នែកទាំងបីខាងក្រោម។

©WIPO/OMPI

## សិទ្ធិផលិតឡើងវិញ

សិទ្ធិរបស់ម្ចាស់សិទ្ធិអ្នកនិពន្ធការពារអ្នកដទៃពីការធ្វើការថតម្លងស្នាដៃរបស់គាត់គឺជាសិទ្ធិមូលដ្ឋានបំផុតក្រោមសិទ្ធិអ្នកនិពន្ធ ។ ឧទាហរណ៍ ការថតចម្លងស្នាដៃដែលបានការពារមួយគឺជាសកម្មភាពដែលបានសម្តែងដោយអ្នកបោះពុម្ពម្នាក់ ដែលចង់ធ្វើការចែកចាយការចម្លងស្នាដៃជាអត្ថបទទៅសាធាណជន ទោះជាក្នុងទម្រង់ថតចម្លងដែលបានបោះពុម្ព ឬពតិមានឌីជីថល ដូចជា ស៊ីឌី រ៉ូមក៏ដោយ។ ដូចគ្នាដែរសិទ្ធិនៃអ្នកផលិតករហ្វូណូក្រាម ផលិតនិងចែកចាយ ស៊ីឌី (CDs) ដែលមានការថតចម្លងការសម្តែងស្នាដៃតន្ត្រីគឺផ្អែកលើការអនុញ្ញាតដោយផ្អែកដែលត្រូវបានផ្តល់ឲ្យដោយអ្នកនិពន្ធបទភ្លេងនៃស្នាដៃនោះ ដើម្បីផលិតឡើងវិញនូវសមាសធាតុទាំងនោះ ក្នុងការថត។

ហេតុដូច្នេះ សិទ្ធិគ្រប់គ្រងសកម្មភាពនៃការផលិតឡើងវិញ គឺជាមូលដ្ឋានស្របច្បាប់សម្រាប់ទម្រង់ជាច្រើននៃការធ្វើអាជីវកម្មនៃស្នាដៃដែលបានការពារ។

សិទ្ធិដទៃទៀត គឺត្រូវបានទទួលស្គាល់ក្នុងច្បាប់ជាតិបន្ថែមទៅលើសិទ្ធិមូលដ្ឋាននៃការផលិតឡើងវិញ។ ឧទាហរណ៍ ច្បាប់មួយចំនួនរួមមានសិទ្ធិអនុញ្ញាឲ្យចែកចាយនូវការចម្លងស្នាដៃជាក់ស្តែងសិទ្ធិផលិតឡើងវិញ គឺជាតម្លៃសេដ្ឋកិច្ចបន្តិចបន្តួច ប្រសិនបើម្ចាស់សិទ្ធិអ្នកនិពន្ធមិនអាចអនុញ្ញាតឲ្យធ្វើការចែកចាយការថតចម្លងដែលបានធ្វើឡើងជាមួយការយល់ព្រមរបស់គាត់។ សិទ្ធិចែកចាយគឺជាកម្មវត្ថុនៃការអស់សិទ្ធិបន្ទាប់ពី ការលក់លើកទី១ ឬការផ្ទេរម្ចាស់សិទ្ធិថតម្លងដទៃទៀត ដែលបានបង្កើតពីការអនុញ្ញាតរបស់ម្ចាស់សិទ្ធិ។ មានន័យថា បន្ទាប់ពីម្ចាស់សិទ្ធិអ្នកនិពន្ធបានលក់ ឬផ្ទេរភាពជាម្ចាស់សិទ្ធិលើការថតចម្លងស្នាដៃជាក់លាក់ណាមួយ ម្ចាស់សិទ្ធិនៃការថតចម្លង អាចប្រើប្រាស់វា ដោយមិនបាច់មានការអនុញ្ញាតបន្ថែមពីម្ចាស់សិទ្ធិអ្នកនិពន្ធ ទោះបោះបង់ចោលឬលក់ឡើងវិញ។

យ៉ាងណាក៏ដោយ ចំពោះការជួលនៃការថតចម្លងទាំងនេះ មានការកើនឡើងច្បាប់សិទ្ធិអ្នកនិពន្ធជាតិ ក៏ដូចជា កិច្ចព្រមព្រៀង(TRIP) បានទទួលស្គាលសិទ្ធិផ្សេងទៀតសម្រាប់កម្មវិធីកុំព្យូទ័រ ស្នាដៃសោតទស្សន៍ និងស្នាដៃហ្វូណូក្រាម ។ សិទ្ធិជួលគឺត្រូវបានយល់ថាត្រឹមត្រូវ ពីព្រោះការជឿនលឿនផ្នែកបច្ចេកវិជ្ជា បានធ្វើឲ្យមានភាពងាយស្រួលក្នុងការថតចម្លងប្រភេទស្នាដៃទាំងនេះ ឧទាហរណ៍ក្នុងប្រទេសមួយចំនួនដែលបានបង្ហាញថាការថតចម្លងគឺត្រូវបានធ្វើឡើងដោយអតិថិជនជួលហាង ហើយដូច្នេះការប្រតិបត្តិសិទ្ធិគ្រប់គ្រង់ការជួលគឺមានសារសំខាន់ដើម្បីការពារម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធលើការផលិតឡើងវិញ។ ជាចុងក្រោយ ច្បាប់សិទ្ធិអ្នកនិពន្ធមួយចំនួនរួម

©WIPO/OMPI

ទាំងសិទ្ធិគ្រប់គ្រងការនាំចូលការថតចម្លងជាមធ្យោបាយមួយក្នុងការការពារការប៉ះពាល់ គោលការណ៍ដែនដីសិទ្ធិអ្នកនិពន្ធ ដែលជាផលប្រយោជន៍សេដ្ឋកិច្ចម្ចាស់សិទ្ធិអ្នកនិពន្ធនឹងធ្វើឲ្យខូចខាត ប្រសិនបើមិនអាចប្រើសិទ្ធិផលិតឡើងវិញ និងសិទ្ធិចែកចាយក្នុងមូលដ្ឋានដែនដីមួយ។

មានសកម្មភាពមួយចំនួននៃការផលិតស្នាដៃមួយឡើងវិញ ដែលជាការលើកលែងចំពោះច្បាប់ទូទៅ ពីព្រោះពួកគេមិនមានតម្រូវការការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់សិទ្ធិដ៏ទៃទៀត ទាំងនេះគឺត្រូវបានដឹងថាជា "ការកម្រិតសិទ្ធិ"។ ឧទាហរណ៍ ច្បាប់ជាតិជាច្រើនជាប្រពៃណីអនុញ្ញាតឲ្យឯកត្តជនធ្វើការថតចម្លងស្នាដៃតែមួយសម្រាប់ឯកជន ផ្ទាល់ខ្លួន និងគោលបំណងមិនមែនពាណិជ្ជកម្ម។ ការផុសឡើងបច្ចេកវិជ្ជាឌីជីថល ដែលបង្កើតលទ្ធភាពផលិតការថតចម្លងស្នាដៃគ្មានការអនុញ្ញាតដែលមានគុណភាពខ្ពស់ដែលមិនអាចសំគាល់បានជាក់ស្តែងពីប្រភព (ហើយដូច្នេះ ជាការជំនួសប្រសើបំផុតសម្រាប់ការទិញការថតចម្លងដែលបានអនុញ្ញាត ឬការទទួលបានដោយត្រឹមត្រូវតាមច្បាប់) ត្រូវបានលើកឡើងជាសំនួរលើការបន្តភាពត្រឹមត្រូវចំពោះការកម្រិតសិទ្ធិលើសិទ្ធិផលិតឡើងវិញ។

©WIPO/OMPI

## សិទ្ធិសម្តែងជាសាធារណៈ សិទ្ធិទូរផ្សាយ និងផ្សព្វផ្សាយជាសាធារណៈ

ជាធម្មតាស្ថិតក្រោមច្បាប់ជាតិ ការសម្តែងជាសាធារណៈ គឺត្រូវបានពិចារណាថាការសម្តែងស្នាដៃមួយចំនួននៅកន្លែងមួយសាធារណៈ ឬអាចមានវត្តមាន ឬនៅទីកន្លែងមួយមិនបើកចំហរជាសាធារណ ប៉ុន្តែទីកន្លែងដែលមានចំនួនមនុស្សច្រើមគួរសមក្រៅពីរង្វង់គ្រួសារធម្មតា និង សង្គមមនុស្សដែលស្គាល់ជិតស្និតបំផុតមានវត្តមាន។

ប៊ិតលើមូលដ្ឋានសិទ្ធិសម្តែងជាសាធារណៈ អ្នកនិពន្ធ ឬម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធដ៏ទៃទៀតអាចនឹងអនុញ្ញាតឲ្យការសម្តែងស្នាដៃជាសាធារណៈផ្ទាល់ ដូចជា ការបង្ហាញការដើរតួមួយក្នុងរោងល្ខោនឬ ការបង្ហាញវង់ភ្លេងនៃបទមហោរីមួយក្នុងសាលប្រគុំតន្ត្រី។ការសម្តែងជាសាធារណៈរួមទាំងការសម្តែងដោយការថតម្លងផងដែរ ដូច្នេះ ស្នាដៃតន្ត្រីដែលបានតំណាងក្នុងហ្វូណូក្រាមគឺត្រូវបានពិចារណាថា "បានសម្តែងជាសាធារណៈ" នៅពេលដែលហ្វូណូក្រាមគឺបានលេងលើឧបករណ៍ដំឡើងសម្លេងក្នុងកន្លែងជាច្រើនដូចការដាក់ថាសម៉ាស៊ីនច្រៀង យន្តហោះ ហាងលក់អីវ៉ាន់ធំៗ។

សិទ្ធិផ្សព្វផ្សាយ គ្របដណ្តប់ការផ្សាយដោយលក្ខណៈអត់មានខ្សែរសម្រាប់សមាជិកនៃសាធារណៈជន ក្នុងលក្ខណៈជាសញ្ញាដែលអនុញ្ញាតឱ្យឧបករណ៍ទទួលសម្លេង ឬរូបភាពនិងសម្លេង ទោះជាដោយវិទ្យុ ទូរទស្សន៍ ឬផ្កាយរណប។

នៅពេលស្នាដៃមួយគឺត្រូវបានផ្សព្វផ្សាយជាសាធារណៈ សញ្ញាមួយគឺត្រូវបានសាយឡើងដោយខ្សែ ឬខ្សែកាប ដែលអាចទទួលបានដោយមនុស្សដែលបានចូលទៅដល់ឧបករណ៍ដែលបានភ្ជាប់ទៅនឹងខ្សែ ឬប្រព័ន្ធខ្សែកាប។

ក្រោមអនុញ្ញាទីក្រុងប៉ែន ម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធមានសទ្ធិផ្តាច់មុខចំពោះការអនុញ្ញាតការសម្តែងជាសាធារណៈ ផ្សព្វផ្សាយ និងទំនាក់ទំនងទៅសាធារណៈជនចំពោះស្នាដៃរបស់ពួកគេ។ ក្រោមច្បាប់ជាតិមួយចំនួន សិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធ ឬម្ចាស់សិទ្ធិដ៏ទៃទៀតដែលអនុញ្ញាតផ្សព្វផ្សាយគឺត្រូវបានជំនួស ក្នុងកាលៈទេសៈពិតប្រាកដ ដោយសិទ្ធិចំពោះការបង់ថ្លៃប្រកបដោយសមធម៌ទោះបីជាការដាក់កំហិតដូចគ្នាលើសិទ្ធិផ្សព្វផ្សាយគឺគ្មាននិងមិនសាមញ្ញក៏ដោយ។

©WIPO/OMPI

## សិទ្ធិនៃការបកប្រែ និងសិទ្ធិនៃការយកលំនាំតាម

អំពើនៃការបកប្រែ ឬការយកលំនាំតាមស្នាដៃមួយត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ ដែលតម្រូវមានការអនុញ្ញាតពីម្ចាស់សិទ្ធិផងដែរ។ ការបកប្រែមានន័យថាការបង្ហាញស្នាដៃមួយក្នុងភាសាមួយ ឬដ៏ទៃទៀតក្រៅពីស្នាដៃដើម។ ការយកលំនាំតាមគឺត្រូវបានយល់ជាទូទៅថាជាការកែប្រែស្នាដៃមួយបង្កើតជាស្នាដៃមួយទៀត ឧទាហរណ៍ ការយកលំនាំតាមប្រលោមលោកមួយបង្កើតជារូបភាពមានចលនា ឬការកែប្រែស្នាដៃមួយធ្វើឲ្យវាសមរម្យសម្រាប់លក្ខខណ្ឌផ្សេងៗគ្នានៃអាជីវកម្ម។ ឧទាហរណ៍ ការកែប្រែអត្ថបទសៀវភៅសិក្សាដើមមួយដែលបានរៀបចំសម្រាប់ការអប់រំជាន់ខ្ពស់ទៅក្នុងអត្ថបទសៀវភៅសិក្សា ដែលបានបម្រុងទុកសម្រាប់សិស្សនៅថ្នាក់ក្រោម។

ការបកប្រែនិងការយកលំនាំតាមគឺជាស្នាដៃដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ។ ហេតុដូច្នេះ ការរៀបចំផលិតឡើងវិញ និងបោះពុម្ភការបកប្រែមួយ ឬការយកលំនាំតាមមួយ ការអនុញ្ញាតត្រូវបានទទួលពីម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធទាំងពីរ ពីស្នាដៃដើមនិងពីម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធក្នុងការបកប្រែ ឬការយកលំនាំតាម។

សិទ្ធិសេដ្ឋកិច្ចនៃប្រភេទសិទ្ធិដែលបានបញ្ជាក់ខាងលើអាចត្រូវបានផ្ទេរ ឬប្រគល់ទៅម្ចាស់ដទៃទៀតជាធម្មតាសម្រាប់ថវិការមួយចំនួន ឬការបង់តម្លៃសិទ្ធិ ផ្អែកលើគោលបំណងនៃការប្រើប្រាស់ស្នាដៃ។ យ៉ាងណាក៏ដោយ ប្រភេទទីពីរនៃសិទ្ធិ សិទ្ធិសីលធម៌ អាចនឹងមិនត្រូវបានផ្ទេរ។ ពួកវាតែងតែ នៅជាមួយអ្នកនិពន្ធដើមនៃស្នាដៃ។

©WIPO/OMPI

ឥឡូវស្តាប់វគ្គសម្លេងបន្ទាប់សម្រាប់ការពិពណ៌នាពីសិទ្ធិសិលធម៌។

វគ្គសម្លេងទី ៣: ឥឡូវ តើអ្វីជាសិទ្ធិសីលធម៌ពិតប្រាកដ?

សិទ្ធិ ដែលខ្ញុំទើបបានបញ្ជាក់គឺត្រូវបានស្គាល់ថាជាសិទ្ធិសេដ្ឋកិច្ច។ សិទ្ធិសីលធម៌គឺផ្សេងគ្នា វាត្រូវបានបង្កើតដោយវត្ថុពីរ ទីមួយគឺភាពជាម្ចាស់សិទ្ធិកនិពន្ធ។ នោះគឺជាសិទ្ធិទាមទារឋាន: អ្នកនិពន្ធស្នាដៃ និងមានភាពជាអ្នកនិពន្ធដែលបានទទួលស្គាល់នោះ។ វាជាសិទ្ធិជាមូលដ្ឋានដែលតម្រូវឱ្យដាក់ឈ្មោះរបស់អ្នកនៅពេលស្នាដៃគឺត្រូវបានផលិតផលិតឡើងវិញ។ ប្រសិនបើអ្នកបាននិពន្ធសៀវភៅមួយ បន្ទាប់មកអ្នកមានសិទ្ធិមួយដោយច្បាប់មានឈ្មោះរបស់អ្នកបញ្ជាក់ជាអ្នកនិពន្ធរបស់សៀវភៅ និងត្រូវបានដាក់ឈ្មោះនៅពេលស្នាដៃត្រូវបានប្រើប្រាស់ យ៉ាងហោចណាស់នៅក្នុងការកំហិតដែលសមហេតុផល។ យើងមិនអាចសង្ឃឹមថាអ្នកចាក់ស៊ីឌីក្នុងកន្លែងរាំអាចប្រកាសពីអ្នកនិពន្ធបទភ្លេង អ្នកនិពន្ធទំនុក អ្នកចាត់ចែង និងជាអាទ៍សម្រាប់គ្រប់ការថតដែលគាត់ចាក់ ប៉ុន្តែប្រសិនបើអ្នកចាក់ស្នាដៃនៅកន្លែងប្រគុំតន្ត្រីមួយ ការប្រគុំតន្ត្រីបែបប្រពៃណីនៃភ្លេងទំនើប អ្នកនិពន្ធបទភ្លេងនឹងដាក់ចំណាងជើងងាយយល់ដែលត្រូវមានការបញ្ជាក់ពីឈ្មោះរបស់គាត់ក្នុងកម្មវិធី។ ជាការពិតគឺអនុវត្តសម្រាប់ស្នាដៃសំខាន់ជាច្រើនដូចជា ការបញ្ចាំងស្នាដៃទាំងនោះក្នុងរោងល្ខោន ឬសាលប្រគុំតន្ត្រី តាមពិតគ្រប់ស្នាដៃទាំងអស់ជាគោលការណ៍ យើងត្រូវដាក់ឈ្មោះអ្នកនិពន្ធ។នេះគឺជាការផ្សព្វផ្សាយដ៏ពិតប្រាកដផងដែរក្នុងករណីមួយចំនួន ប៉ុន្តែមិនគ្រប់ពេលទាំងអស់នោះទេ។ ក្រៅពីនេះ ការថ្លឹងថ្លែងពិតប្រាកដលំអិតគឺជាអ្វីៗដែលទាក់ទងនឹងច្បាប់ជាតិ ជាទូទៅយោងលើការអនុវត្តន៍ និងអ្វីដែលមានពីមុនមក។

សិទ្ធិសីលធម៌គឺជាសិទ្ធិនៃការគោរព ដែលគឺជា សិទ្ធិជំទាស់ទៅនឹងការកែប្រែឬប្រើប្រាស់ស្នាដៃ ដែលធ្វើឱ្យប៉ះពាល់ដល់ កិត្តិយស និងកេរ្តិ៍ឈ្មោះអក្សរសាស្ត្រ និងសិល្បៈរបស់អ្នកនិពន្ធ។ អ្នកនិពន្ធអាចជំទាស់នឹងការប្រើប្រាស់ស្នាដៃរបស់គាត់ក្នុងបរិបទកាមសាស្ត្រ ប្រសិនបើស្នាដៃគឺមិនមែនមានលក្ខណៈជាកាមសាស្ត្រ។ ហើយអ្នកនិពន្ធអាចជំទាស់នឹងការកែប្រែខ្លឹមសារស្នាដៃដែលធ្វើឱ្យប៉ះពាល់ដល់បូរណភាពវប្បធម៌ ឬសិល្បៈ។

©WIPO/OMPI

## សំនួរវាយតម្លៃខ្លួនឯង(SAQ)

SAQ 3: សន្មតថាអ្នកបានក្លាយជាសិល្បករម្នាក់ ដោយអាស្រ័យនូវបំណែកនៃចំណេះដឹងសិល្បៈដែលបានអបអរសាទរជាអន្តរជាតិ ដែលជាវិភាគទាន ដល់ការអភិរក្សធម្មជាតិ និងក្រោយមកអ្នកឃើញថាវាគឺកំពុងត្រូវបានប្រើប្រាស់ ក្នុងការសម្តែងម៉ូតបន្ទុះបង្អាប់ ដោយគ្មានការអនុញ្ញាតរបស់អ្នក ដោយក្រុមនយោបាយធម្មតាមួយក្រុមកំពុងគាំទ្រ បានកែប្រែសរីរៈទូទៅ ។ តើអ្នកនឹងធ្វើអ្វី?

សរសេរចំលើយរបស់អ្នកទីនេះ

ចុចទីនេះសម្រាប់ចំលើយ

©WIPO/OMPI

SAQ 3 ចំលើយ

ប្រសិនបើអ្នកបានរក្សាសិទ្ធិសេដ្ឋកិច្ចពាក់ព័ន្ធ អ្នកអាចនឹងហាមឃាត់ការប្រើប្រាស់ក្រោមសិទ្ធិទាំងនោះ។ ប្រសិនបើអ្នកបានផ្ទេរសិទ្ធិទាំងនោះមុន ការប្រើប្រាស់ដែលមិនមានការអនុញ្ញាត អ្នកនឹងនៅតែអាចបញ្ឈប់ ការប្រើប្រាស់សិទ្ធិក្រោមសិទ្ធិសីលធម៌ទាក់ទងនឹងការគោរពសិទ្ធិនៃការគោរព។

©WIPO/OMPI

អ្នកគួរតែបានដឹងពីប្រភេទនៃស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ដែលត្រូវបានគ្របដណ្តប់ដោយសិទ្ធិអ្នកនិពន្ធ និងប្រភេទនៃសិទ្ធិដែលម្ចាស់សិទ្ធិអ្នកនិពន្ធម្នាក់មាន និងអ្នកអាចនឹងងឿងឆ្ងល់ ថាតើហេតុអ្វីបានជាអ្នកនិពន្ធស្នាដៃដូចគ្នាមួយទទួលសិទ្ធិអ្នកនិពន្ធសម្រាប់ស្នាដៃនោះ។ ស្តាប់វគ្គសម្លេងបន្ទាប់ដើម្បីដឹង

វគ្គសម្លេងទី ៤: តើអ្នកអាចប្រាប់យើងបន្តិចអំពីថាតើសិទ្ធិអ្នកនិពន្ធគឺជាការពិតបានទទួលឬ?

គ្មានបញ្ហាឡើយ ការពិតវាគឺសាមញ្ញ។ អ្នកមិនចាំបាច់ធ្វើអ្វីនោះទេ ក្រោមអនុសញ្ញាទីក្រុងប៊ែន ដែលគ្មានកំណត់ពីទម្រង់នៃស្នាដៃនោះទេ។ ជាមូលដ្ឋាន ស្នាដៃរបស់អ្នកគឺត្រូវបានការពារដោយដំណើរការច្នៃប្រឌិតដោយខ្លួនវាផ្ទាល់។ យ៉ាងណាក៏ដោយ ក្រោមច្បាប់ជាតិមួយចំនួន គួរគត់សម្គាល់ក្នុងប្រទេស common Law ស្នាដៃ មិនចាំបាច់ថតបញ្ចូលជាមុនដើម្បីទទួលបានការការពារនោះទេ។

ដោយការថតបញ្ចូល តើអ្នកចង់មានន័យយ៉ាងម៉េច?

បានកត់ត្រា ឬថតចម្លង។ អ្នកមិនធ្លាប់បានថតស្នាដៃដោយខ្លួនអ្នកផ្ទាល់ ប្រសិនបើអ្នកតែងបទភ្លេងមួយ បន្លឺសូរហ៊ឹម (hum) គាប់ជូនលើផ្លូវ ហើយខ្ញុំបានថតវាទុក ពេលនោះវាត្រូវបានថតបញ្ចូល។ ប៉ុន្តែវាក៏មានន័យថាត្រូវបានការពារដែរ ដូច្នេះពេលនោះប្រសិនបើខ្ញុំយកវាមកធ្វើការថតចម្លងនូវបទភ្លេងរបស់អ្នក សម្រាប់ការផលិតឡើងវិញឲ្យប្រសើឡើងជាឧទាហរណ៍ ខ្ញុំនឹងរំលោភសិទ្ធិអ្នកនិពន្ធរបស់អ្នក។ ភាពភាពខុសគ្នាទីនេះគឺពិតជាមិនមានសារសំខាន់នោះទេ វាគឺជាសំនួរមូលដ្ឋានមួយពីប្រភេទភស្តុតាងដែលអ្នកនឹងត្រូវការក្នុងតុលាការ ក្នុងរឿងក្តីស្នាដៃដ៏កម្របំផុតដែលត្រូវបានកំណត់ក្នុងរបៀបធម្មតា ដូចជាការទម្លាប់និយមរបាំបាឡេ។ សព្វថ្ងៃនេះ អ្នកអាចថតបញ្ចូលរបាំបាឡេក្នុងវិដេអូ និងប្រើប្រាស់ប្រភេទនៃការនិពន្ធជាពិសេសមួយបង្កើតការតែងឬរាំរបាំ ប៉ន្តែការធ្វើដូចនេះមិនសូវមានការវិវត្តទេរហូតដល់សព្វថ្ងៃ។ ទីនោះអាចជាបញ្ហាមួយ ប្រសិនបើអ្នកបានអះអាងថា អ្នកបានបង្កើតរបាំបាឡេមួយ ហើយនរណាម្នាក់បានបង្កើតការសម្តែងអំពីវា។ អ្នកកាត់សេចក្តីពេលនោះអាចនិយាយថា "ល្អ អាចឲ្យខ្ញុំបង្ហាញភស្តុតាងមួយចំនួនដែលមានស្រាប់អំពីស្នាដៃរបស់អ្នក" ប្រសិនបើមិនត្រូវបានដាក់ចេញជាទម្រង់ណាមួយភ័ស្តុតាអាចនឹងពិបាកក្នុងការផ្តល់ឱ្យ។ ហើយក្នុងប្រទេសច្បាប់ Civil Law ស្នាដៃគឺត្រូវបានការពារចាប់ពីពេលបង្កើតវា។ ដូច្នេះសូម្បីតែអ្នកនឹករកកំណាព្យក្នុងខួរក្បាលរបស់អ្នកនោះ វាក៏ត្រូវបានការពារផងដែរ។ វានឹងជាបញ្ហារបស់អ្នក ជាការពិតក្នុងការបង្ហាញភស្តុតាងពីការបង្កើត

©WIPO/OMPI

កំណាព្យ ។ ក្រោមច្បាប់ Common Law អ្នកអាចត្រូវបានតម្រូវឱ្យបង្កើតក្នុងទម្រង់ណាមួយ ដូចជា សំណេរ ឬថតចម្លងក្នុងថេប។

តើមានកន្លែងណាមួយក្នុងពិភពលោកដែលអ្នកត្រូវគោរពតាមបែបបទជាក់លាក់ដើម្បីទទួលបានសិទ្ធិអ្នកនិពន្ធ?

ក្នុងប្រទេសដែលជាសមាជិកអនុសញ្ញាទីក្រុងប៉ែន ម្ចាស់សិទ្ធិ ឬ អ្នកនិពន្ធបរទេសទាំងអស់នៃប្រទេសសមាជិកទីក្រុងប៉ែនដទៃទៀត ដែលមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់កិច្ចការពារ ក្រោមអនុសញ្ញាគ្មានកំណត់ពីបែបបទនោះទេ ដូច្នេះមិនមានតម្រូវការបង្កើតការចុះបញ្ជីនោះទេ។ ប្រទេសមួយចំនួន អាចតម្រូវឱ្យពលរដ្ឋរបស់ខ្លួនគោរពបែបបទ ដោយសារអនុសញ្ញាអន្តរជាតិទាក់ទងតែជាមួយនឹងប្រព្រឹត្តិកម្មចំពោះពលរដ្ឋបរទេស ។ ជាគោលការណ៍ប្រទេសមួយអាចកំណត់ចចំពោះពលរដ្ឋរបស់ខ្លួន។ ឧទាហរណ៍ ក្នុងសហរដ្ឋអាមេរិក មានប្រវត្តិនៃលក្ខខណ្ឌតម្រូវចាស់ ដែលតម្រូវឱ្យធ្វើការចុះបញ្ជីនៅការិយាល័យសិទ្ធិអ្នកនិពន្ធ ដែលជាផ្នែកមួយនៃ Library of Congress ហើយ ក្នុងការទាមទារ សិទ្ធិអ្នកនិពន្ធ តាមរយៈសេចក្ដីជូនដំណឹងពីការរក្សាសិទ្ធិ អក្សរCគូររង្វង់ ដែលអ្នកប្រហែលជាបានឃើញក្នុងសៀវភៅសំខាន់ជាច្រើន បន្ទាប់មកមានឆ្នាំនៃកាលបរិច្ឆេទនៃការបោះពុម្ពដំបូង។

អ្វីទាំងនេះគឺពិតជាមានសារៈសំខាន់ជាពិសេសសម្រាប់ស្នាដៃជនជាតិអាមេរិក។ ដូច្នេះសម្រាប់ស្នាដៃជនជាតិអាមេរិក សហរដ្ឋ តម្រូវឱ្យពិនិត្យលើ អ្វីៗដែលស្នាដៃបរទេសអាចធ្វើឱ្យប្រសើរឡើងសម្រាប់ កិច្ចការពារដែលហួសពីអ្វីដែលត្រូវបានផ្ដល់ដោយអនុសញ្ញាទីក្រុងប៉ែន ដូច្នេះចំពោះស្នាដៃពិតប្រាកដ ដែលត្រូវបានពិចារណាជាផលប្រយោជន៍ពិសេសចំពោះទីផ្សារអាមេរិក ចាំបាច់ត្រូវពិនិត្យពីប្រព័ន្ធចុះបញ្ជីនៃប្រទេសនោះ ។ អាចធ្វើដូច្នេះ ប៉ុន្តែ វាមានកិច្ចការពារតាំងពីដើមដំបូង ដូនេះ តាមការពិតវាគឺមិនចាំបាច់ធ្វើអ្វីនៅទេ និងលក្ខណៈបែបនេះ មានចំពោះគ្រប់ប្រទេសជាសមាជិកអនុសញ្ញាទីក្រុងប៉ែន។

©WIPO/OMPI

## សំនួរវាយតម្លៃ ខ្លួនឯង(SAQ)

SAQ 4: គិតស្រមៃថាអ្នកគឺជាពលរដ្ឋម្នាក់នៃនៃប្រទេសមួយ ដែលបានចុះហត្ថលេខាក្នុងអនុសញ្ញាទីក្រុងប៉ែន ហើយអ្នកបង្កើតស្នាដៃអក្សរសាស្ត្រមួយ។ តើអ្នកត្រូវចាត់វិធានការបែបណាខ្លះ ដើម្បីទទួលបានសិទ្ធិអ្នកនិពន្ធចំពោះស្នាដៃ?

សរសេរចំលើយរបស់អ្នកទីនេះ

ចុះទីនេះសម្រាប់ចំលើយ

©WIPO/OMPI

SAQ 4 ចំលើយ:

ក្នុងលក្ខខណទូទៅគឺងាយស្រួលបំផុត មិនមានអ្វីដែលត្រូវធ្វើនោះទេ។ អនុសញ្ញាទីក្រុងប៊ែនបង្កើតគោលការណ៍គ្មានលក្ខខណ្ឌទម្រង់ ការបង្កើតឡើង ស្មើនឹងកិច្ចការពារ។

ក្នុងប្រទេសCommon Law ភាគច្រើនរតម្រូវឱ្យមានការបង្កើតឡើងក្នុងទម្រង់ណាមួយ ស្នាដៃត្រូវតែត្រូវមានការកត់ត្រា ឬថតចម្លង។ ជាឧទាហរណ៍ របាំបាឡេ ដំបូងឡើយគឺបានសំគាល់ក្នុងកំណត់របាំ ហើយបច្ចុប្បន្នបានថតចម្លងជាវិដេអូ។

ក្នុងប្រទេស civil law ស្នាដៃគឺត្រូវបានការពារពីពេលបង្កើតឡើង ដែលនៅតែមានបញ្ហាសម្រាប់ការអនុវត្តពីការបង្កើតឡើងក្នុងតុលាការ។ គួរកត់សម្គាល់ថាអាចតម្រូវឱ្យមានទម្រង់បែបបទក្រោមច្បាប់ជាតិសម្រាប់កិច្ចការពារចំពោះប្រជាពលរដ្ឋខ្លួន។ ក្នុងប្រទេសអនុសញ្ញាទីក្រុងប៊ែន ម្ចាស់សិទ្ធិបរទេសទាំងអស់ ក្រៅពីរដ្ឋសមាជិកអនុសញ្ញាទីក្រុងប៊ែនមានកិច្ចការពារដោយគ្មានទទម្រង់បែបបទ(គ្មានការចុះបញ្ជី)។

©WIPO/OMPI

## ការផ្ទេរសិទ្ធិអ្នកនិពន្ធ

ស្នាដៃច្នៃប្រឌិតជាច្រើន ដែលបានការពារដោយសិទ្ធិអ្នកនិពន្ធតម្រូវការវិនិយោគហិរញ្ញវត្ថុ និងជំនាញវិជ្ជាជិវៈសម្រាប់ផលិតកម្មរបស់ពួកគេ និងជួយជ្រោមជ្រែងការផ្សព្វផ្សាយ និងបណ្តុំការចែកចាយ។សកម្មភាពជាច្រើនដូចជាការបោះពុម្ពសៀវភៅ ការថតចម្លងបទភ្លេង ឬការផលិតភាពយន្តគឺធ្វើឡើងដោយអង្គការពាណិជ្ជកម្មឯកទេស ឬក្រុមហ៊ុន មិនមែនធ្វើដោយផ្ទាល់ដោយអ្នកនិពន្ធឡើយ។ ធម្មតា អ្នកនិពន្ធ និងអ្នកបង្កើតផ្ទេរសិទ្ធិរបស់ពួកគេទៅឱ្យក្រុមហ៊ុនទាំងនេះដោយរបៀបជាកិច្ចសន្យាកិច្ច ជាថ្នូមកវិញនូវការបង់កម្រៃ។ ការបង់កម្រៃអាចមានទម្រង់ផ្សេងៗ ដូចជា ការបង់សរុបតែម្តង ឬលាភការផ្អែកលើភាគរយនៃផលទុនដែលបានបង្កើតដោយស្នាដៃ។

ការផ្ទេរ អាចមានឥទ្ធិពលលើសិទ្ធិបេតិកភ័ណ្ឌទាំងអស់ ឬមួយចំនួន (ការផ្ទេរសិទ្ធិដោយផ្នែក)។ ឧទាហរណ៍ អ្នកនិពន្ធប្រលោមលោកជាភាសាអង់គ្លេសម្នាក់ អាចលក់ទៅឲ្យអ្នកបោះពុម្ពម្នាក់នូវការផលិតឡើងវិញ និងសិទ្ធិចែកចាយរបស់គាត់ ក៏ដូចជាសិទ្ធិបកប្រែ និងយកលំនាំតាមរបស់គាត់ក្នុងប្រលោមលោក។ ប៉ុន្តែអ្នកនិពន្ធប្រហែលជ្រើសយករបៀបផ្សេងពីនេះ គាត់ប្រហែលជាសម្រេចចិត្តបំបែកសិទ្ធិដែលគាត់មានរវាងមនុស្សផ្សេងៗ។ ដូច្នេះ អ្នកនិពន្ធប្រលោមលោក អាចផ្ទេរសិទ្ធិត់បោះពុម្ព និងផលិតឡើងវិញនូវប្រលោមលោកដែលបាននិពន្ធក្នុងភាសាអង់គ្លេសទៅឲ្យអ្នកបោះពុម្ពម្នាក់។ គាត់ប្រហែលជាផ្ទេរសិទ្ធិបកប្រែបលោមលោកទៅជា ភាសាបារាំង រុស្ស៊ី និងអារាប់ ទៅជាអ្នកបោះពុម្ពផ្សេងៗបីអ្នកទៀត។ បន្ថែមពីនេះ គាត់ប្រហែលជាផ្ទេរសិទ្ធិត្រាបតាមប្រលោមលោករបស់គាត់ទៅជាភាពយន្ត(ឬ ល្ខោន ឬការសម្តែងមួយ) ទៅមនុស្សផ្សេងៗ។

ការផ្ទេរប្រហែជាត្រូវបានអនុញ្ញាតសម្រាប់កំឡុងពេលជាក់លាក់មួយ និងដែនដីដែលបានកំណត់ ឬសម្រាប់រយៈពេលនៃលក្ខខ័ណ្ឌពេលលេញនៃសិទ្ធិអ្នកនិពន្ធ និងទូទាំងពិភពលោក។ ហេតុនេះ ម្ចាស់សិទ្ធិអ្នកនិពន្ធប្រលោមលោកមួយអាចផ្ទេរសិទ្ធិ ទៅឲ្យអ្នកបោះពុម្ពម្នាក់នូវសិទ្ធិបោះពុម្ពសៀវភៅជាភាសាអង់គ្លេស សម្រាប់ដែនដីជាក់លាក់មួយ ពោល សហរដ្ឋអាមេរិក និងសម្រាប់កំឡុងពេល ២០ ឆ្នាំ។ ឬគាត់ប្រហែលជាសម្រេចចិត្តផ្ទេរសិទ្ធិទៅមនុស្សដដែលនូវសិទ្ធិបោះពុម្ពប្រលោមលោកជាភាសាអង់គ្លេសទូទាំងពិភពលោក និងសម្រាប់កំឡុងពេលសិទ្ធិអ្នកនិពន្ធ។ ការរួមបញ្ចូលគ្នានេះ គឺមានច្រើន និងអាស្រ័យលើការចរចាររវាងគូរភាគី។

©WIPO/OMPI

ដូចដែលយើងបានឃើញ ការផ្ទេរសិទ្ធិមានវិបាកជាសំខាន់ដល់អ្នកនិពន្ធ។ តាមច្បាប់ អ្នកទទួលសិទ្ធិ(មនុស្សដែលបានសិទ្ធិ ឬសិទ្ធិត្រូវបានទទួលការផ្ទេរសិទ្ធិ)គឺត្រូវបានផ្ទេរសិទ្ធិដោយកិច្ចសន្យាដល់គាត់។ ដូច្នេះគាត់ក្លាយជាម្ចាស់សិទ្ធិថ្មី សម្រាប់រយៈពេល និងដែនដីដែលបានព្រមព្រៀង។ ដូច្នេះ វាគឺមានសារៈសំខាន់ដែលអ្នកនិពន្ធដឹងយ៉ាងច្បាស់អំពីហេតុបច្ច័យពីប្រត្តិបត្តិការមួយដូចគ្នា។ នេះគឺជាហេតុដែលច្បាប់សិទ្ធិអ្នកនិពន្ធជាតិជាច្រើនតម្រូវឱ្យមានបទប្បញ្ញាត្តិស្តីពីការផ្ទេរសិទ្ធិ គឺត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយ ឬក្នុងនាមអ្នកផ្ទេរសិទ្ធិ ដើម្បីឱ្យនឹងយកជាការបាន ឬឱ្យមានប្រសិទ្ធភាព។ ការតម្រូវបែបនេះ ជួយធ្វើឲ្យប្រាកដថាអ្នកនិពន្ធគឺយល់ដឹងយ៉ាងច្បាស់អំពីសិទ្ធិដែលគាត់មាន ក្នុងតម្លៃប៉ុន្មាន និងមានលក្ខខណ្ឌអ្វីខ្លះ។

©WIPO/OMPI

សំនួរបន្ទាប់ អ្នកប្រហែលជាអាចសួរថា នៅពេលដែលខ្ញុំទទួលបានសិទ្ធិអ្នកនិពន្ធ តើរយៈពេលប៉ុន្មានដែលស្នាដៃរបស់ខ្ញុំត្រូវបានការពារ?

សម្លេងវគ្គទី ៥: តើរយៈពេលប៉ុន្មានដែលសិទ្ធិអ្នកនិពន្ធការពារ?

ជាគោលការណ៍ លើកលែងតែច្បាប់ជាតិចែងផ្សេង រយៈពេលការពារអប្បរមាក្រោមអនុសញ្ញាទីក្រុងប៊ែនគឺ ៥០ ឆ្នាំ។ រយៈពេលគឺត្រូវបានគណនាពីដំណាច់ឆ្នាំនៃការស្លាប់របស់អ្នកនិពន្ធ អ្នកមិនបាច់គិតពីថ្ងៃដែលគាត់ស្លាប់នោះទេ អ្នកត្រូវការត្រឹមដឹងតែឆ្នាំ។ ប៉ុន្តែមានការនិន្នាការពន្យារកិច្ចការពារនាពេលបច្ចុប្បន្ន។ ក្នុងសហភាពអឺរ៉ុប និងសម្រាប់ប្រទេសនៃតំបន់សេដ្ឋកិច្ចសហភាពអឺរ៉ុប រយៈពេលគឺ ៧០ ឆ្នាំពីដំណាច់ឆ្នាំនៃការស្លាប់របស់អ្នកនិពន្ធ និង រយៈពេលដូចគ្នាដែលបានកត់ត្រាទៅក្នុងច្បាប់របស់សហរដ្ឋអាមេរិក ដូច្នេះគឺដូចគ្នាគឺ ៧០ ឆ្នាំ។ ដូច្នេះមាននិន្នាការពន្យាររយៈពេលការពារពី ៥០ ទៅ ៧០ ឆ្នាំ។

សូមចំណាំថា យ៉ាងណាក៏ដោយមានករណីដែលក្នុងអនុសញ្ញាទីក្រុងប៊ែនតម្រូវការអប្បរមាគឺតិចជាង ៥០ ឆ្នាំក្រោយមរណភាព។ ឧទាហរណ៍ សម្រាប់ស្នាដៃហ្វូណូក្រាម និងស្នាដៃសិល្បៈអនុវត្ត រយៈពេលអប្បរមានៃកិច្ចការពារគឺ ២៥ ឆ្នាំបន្ទាប់ពីការបង្កើតស្នាដៃ។

©WIPO/OMPI

## សំនួរវាយតម្លៃខ្លួនឯង(SAQ)

SAQ 5: តើរយៈពេលអប្បរមានៃកិច្ចការពារសិទ្ធិអ្នកនិពន្ធក្រោមអនុសញ្ញាទីក្រុងប៊ែនមានរយៈពេលប៉ុន្មាន? តើមានការផ្លាស់ប្តូរយ៉ាងដូចម្តេច?

សរសេរចម្លើយរបស់អ្នកទីនេះ

ចុះទីនេះសម្រាប់ចម្លើយ

©WIPO/OMPI

SAQ 5 ចម្លើយ:

រយៈពេលអប្បបរមានៃកិច្ចការពារក្រោមអនុសញ្ញាទីក្រុងប៊ែនគឺ ៥០ ឆ្នាំ ចាប់ពីថ្ងៃដែលអ្នកនិពន្ធស្លាប់។ រយៈពេលនេះត្រូវបានពន្យារដោយប្រទេសមួយចំនួនដូចជាប្រទេសសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ទៅ ៧០ឆ្នាំ ចាប់ពីការស្លាប់របស់អ្នកនិពន្ធ។ យ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន កិច្ចការពារក្រោមអនុសញ្ញាទីក្រុងប៊ែនគឺតិចជាង ៥០ ឆ្នាំ បន្ទាប់ពីការស្លាប់របស់អ្នកនិពន្ធ។

©WIPO/OMPI

ឥឡូវនេះ ដល់ពេលឱ្យអ្នកពិចារណាពីការកម្រិតសិទ្ធិទូទៅនៃម្ចាស់សិទ្ធិអ្នកនិពន្ធ ដែលមានក្រោមច្បាប់ជាតិមួយចំនួន។

## ការកម្រិតសិទ្ធិ

និយាយក្នុងលក្ខណៈចង្អៀត ការកម្រិតសិទ្ធិដំបូងគឺជាការលើកលែងចេញពីកិច្ចការពារសិទ្ធិអ្នកនិពន្ធអំពីប្រភេទស្នាដៃមួយចំនួន។ ក្នុងប្រទេសមួយចំនួន ស្នាដៃ ត្រូវបានដកចេញពីកិច្ចការពារ ប្រសិនបើស្នាដៃទាំងនោះ មិនត្រូវបានធ្វើឡើងក្នុងទម្រង់រូបិយណាមួយ ជាឧទាហរណ៍ ស្នាដៃនាដកម្មនឹងបានការពារនៅពេលដែលមានការកត់ត្រាចលនា ក្នុងកំណត់ត្រារបាំ ឬបានថតចម្លងក្នុងវីដេអូថេប។ ក្នុងប្រទេសមួយចំនួន(មិនទាំងអស់) អត្ថបទច្បាប់ តុលាការ និងការសម្រេចចិត្តរដ្ឋបាលត្រូវបានដកចេញពីកិច្ចការពារសិទ្ធិអ្នកនិពន្ធ។

ប្រភេទនៃការកម្រិតសិទ្ធិទីពីរលើសិទ្ធិរបស់អ្នកនិពន្ធ និងម្ចាស់សិទ្ធិអ្នកនិពន្ធដ៏ទៃទៀត ទាក់ទងនឹងសកម្មភាពនៃការធ្វើអាជីវកម្ម ជាធម្មតាតម្រូវឱ្យមានការការអនុញ្ញាតពីម្ចាស់សិទ្ធិ ដែលក្រោមកាលៈទេសៈជាក់លាក់ដែលមានចែងក្នុងច្បាប់ អាចធ្វើឡើងដោយ គ្មានការអនុញ្ញាត។ មានការកម្រតិសិទ្ធិពីរប្រភេទជាមូលដ្ឋានក្នុងប្រភេទនេះ

១. **ប្រើប្រាស់ដោយសេរី** ដែលជាសកម្មភាពនៃការធ្វើអាជីវកម្មស្នាដៃ ដែលគ្មាន ការអនុញ្ញាត និងគ្មានកាតព្វកិច្ចទូទាត់សងដល់ម្ចាស់សិទ្ធិសម្រាប់ការប្រើប្រាស់។

២. **អាជ្ញាប័ណ្ណបញ្ញា**ដែលសកម្មភាពធ្វើអាជីវកម្ម អាចធ្វើឡើងដោយគ្មានការអនុញ្ញាត ប៉ុន្តែ*មាន*កាតព្វកិច្ចទូទាត់សងម្ចាស់សិទ្ធិ។

ឧទាហរណ៍សម្រាប់ការប្រើប្រាស់ដោយសេរី រួមមានអាគតដ្ឋានពីស្នាដៃដែលបានការពារឱ្យតែផ្តល់ប្រភពនៃអាគតដ្ឋានោះ រួមទាំង ឈ្មោះអ្នកនិពន្ធ គឺត្រូវបានបញ្ជាក់ និងទំហំនៃការដាក់តម្លៃនោះគឺអាចយល់ព្រមបានជាមួយនឹងការអនុវត្តន៍ត្រឹមត្រូវ ការប្រើប្រាស់ស្នាដៃដោយមធ្យោបាយលំអរដោយរូបសម្រាប់គោលបំណងបង្រៀន និងការប្រើប្រាស់ស្នាដៃសម្រាប់គោលបំណងរាយការណ៍ព័ត៌មាន។ ចំពោះសិទ្ធិផលិតឡើងវិញ អនុសញ្ញាទីក្រុងប៊ែនមានវិធានទូទៅ ជាជាងការពិណនាលម្អិតពីការកម្រិត មាត្រា ៩ (២) កំណត់ថារដ្ឋជាសមាជិកប្រហែលជាផ្តល់សម្រាប់ការផលិតឡើងវិញដោយសេរីក្នុង "ករណីពិសេសមួយចំនួន" ដែលមិនធ្វើឲ្យប៉ះពាល់ដល់ការធ្វើអាជីវកម្មជាធម្មតា និងមិនធ្វើឲ្យខូចប្រយោជន៍ ស្របច្បាប់របស់អ្នកនិពន្ធ។ ដូចដែលបានកំណត់ខាងលើ ច្បាប់ជាច្រើនមានបទបញ្ញត្តិពីការអនុញ្ញាតការផលិតឡើងវិញនូវស្នាដៃមួយផ្តាច់មុខ

©WIPO/OMPI

សម្រាប់ការប្រើប្រាស់លក្ខណៈបុគ្គល ឯកជន និងការប្រើប្រាស់មិនមែនពាណិជ្ជកម្ម។ យ៉ាងណាក៏ដោយ ភាពងាយស្រួល និងគុណនៃភាពការថតចម្លងផ្ទាល់ខ្លួននេះ អាចធ្វើទៅបានដោយការថតសម្លេង ឬថតវីដេអូ និងការធ្វើឲ្យប្រសើឡើងបច្ចេកវិទ្យាបច្ចុប្បន្នជាច្រើន ដែលធ្វើឱ្យប្រទេសមួយចំនួនបង្រួមវិសាលភាពនៃបទបញ្ញត្តិនេះ។ ប្រព័ន្ធច្បាប់មួយចំនួនអនុញ្ញាតឲ្យមានការថតចម្លង ប៉ុន្តែមានយន្តការសម្រាប់បង់កម្រៃដល់ម្ចាស់សិទ្ធិ ចំពោះការធ្វើឱ្យខូចខាតដល់ផលប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគេ តាមរយៈការដាក់កម្រៃការលក់ថែបទទេ និងឬ តាឧបករណ៍ថត។

ជាការបន្ថែមចំពោះការប្រើប្រាស់ដោយសេរី ដែលបានពន្យល់ក្នុងច្បាប់ជាតិ ច្បាប់របស់ប្រទេសមួយចំនួនទទួលស្គាល់ថាជា**ការប្រើប្រាស់ដ៏ត្រឹមត្រូវ** ឬ **កិច្ចព្រមព្រៀងដ៏ត្រឹមត្រូវ** ដែលអនុញ្ញាតឲ្យប្រើប្រាស់ស្នាដៃដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ កត្តាដែលយកមកគិតថាដូចខាងក្រោម៖ ធម្មជាតិ និងគោលបំណងនៃការប្រើប្រាស់ រាប់បញ្ចូលទាំងថាតើ សម្រាប់គោលបំណងពាណិជ្ជកម្ម ធម្មជាតិនៃស្នាដៃដែលបានប្រើប្រាស់ ចំនួនស្នាដៃដែលបានប្រើប្រាស់ក្នុងទំនាក់ទំនងទៅនឹងស្នាដៃទាំងមូល និងប្រសិទ្ធភាពនៃការប្រើប្រាស់ក្នុងតម្លៃពាណិជ្ជកម្មដែលមានសក្តានុពលពីស្នាដៃ។

ដូចដែលបានអធិប្បាយខាងលើ អាជ្ញាប័ណ្ណបញ្ជា អនុញ្ញាតឲ្យប្រើប្រាស់ស្នាដៃក្នុងកាលៈទេសៈពិតប្រាកដដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ប៉ុន្តែតាមការប្រតិបត្តិច្បាប់ តម្រូវឲ្យមានសំណងដោយយោងតាមការប្រើប្រាស់។ អាជ្ញាប័ណ្ណនេះគឺត្រូវបានហៅថា "អាជ្ញាប័ណ្ណបញ្ជា" ពីព្រោះពួកគេគឺត្រូវបានអនុញ្ញាតដោយច្បាប់ និងអាចលើកលែងពីសិទ្ធិផ្តាច់មុខរបស់ អនុញ្ញាតដោយច្បាប់ពិសេស។ អាជ្ញាប័ណ្ណបញ្ជាគឺជាទូទៅត្រូវបានបង្កើតឡើងក្នុងកាលៈទេសៈ ដែលមានការកើតឡើងនូវបច្ចេកវិជ្ជាថ្មីមួយ សម្រាប់ផ្សព្វផ្សាយស្នាដៃដល់សាធារណជនហើយច្បាប់ជាតិមានការព្រួយបារម្ភថា ម្ចាស់សិទ្ធិរារាំងដល់ការអភិវឌ្ឍបច្ចេកវិជ្ជាថ្មីដោយការបដិសេធមិនអនុញ្ញាតឱ្យប្រើប្រាស់ស្នាដៃ។ នេះជាការពិតក្នុងអនុសញ្ញាតទីក្រុងប៊ែន ដែលបានទទួលស្គាល់ទម្រង់ពីរនៃអាជ្ញាប័ណ្ណ៖ ទីមួយ អនុញ្ញាតឱ្យមានការផលិតឡើងវិញបែបមេកានិចនូវស្នាដៃដូរដន្ត្រី និងទីពីរ សម្រាប់ការផ្សព្វផ្សាយ។ គួរកត់សម្គាល់ថា យ៉ាងណាក៏ដោយ ការបង្ហាញភស្តុតាសម្រាប់អាជ្ញាប័ណ្ណបញ្ជា ត្រូវបានលើកឡើងជាសំនួរជាច្រើន ចាប់តាំងពីមានជម្រើសដ៏មានប្រសិទ្ធភាពសម្រាប់ផ្សព្វផ្សាយស្នាដៃជាសាធារណៈ ដោយផ្អែកលើ ការអនុញ្ញាតដែលបានផ្តល់ឲ្យដោយម្ចាស់សិទ្ធិ រួមទាំងក្នុងទម្រង់ជាការគ្រប់គ្រងសិទ្ធិរួម។

ទោះស្ថានភាពណាក៏ដោយ ក្នុងប្រទេសរបស់អ្នកចំពោះសិទ្ធិអ្នកនិពន្ធ អាចនឹងមានស្ថានភាពដែលមិនអាចជៀសវាងបានដែលកំពុងមានការរំលោភសិទ្ធិអ្នកនិពន្ធ ដូច្នេះវាគឺមានសារៈសំខាន់ពិចារណាអំពីប្រភេទនៃវិធានការដោះស្រាយដែលម្ចាស់សិទ្ធិអ្នកនិពន្ធត្រូវចាត់។

## ការអនុវត្តន៍សិទ្ធិ

អនុសញ្ញាទីក្រុងប៉ែរិនមានបញ្ញត្តិខ្លះពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិ ប៉ុន្តែមានការវិវត្តន៍ស្តង់ដារជាតិ និងស្តង់ដារអន្តរជាតិថ្មីគួរឱ្យកត់សម្គាល់ក្នុងពេលថ្មីៗនេះ ដោយកត្តាធំពីរ។ ទី១ គឺជាការជឿនលឿននៃមធ្យោបាយបច្ចេកវិជ្ជាអំពីការបង្កើត និងការប្រើប្រាស់ (ទាំងទទួលបានអនុញ្ញាត និងមិនបានអនុញ្ញាត) នៃស្នាដៃដែលបានការពារ និងជាពិសេស បច្ចេកវិជ្ជាឌីជីថលដែលអាចបង្កើតទៅបានដើម្បីបញ្ជូន និងចម្លងឲ្យល្អបំផុតអំពីព័ត៌មានមួយចំនួន ដែលមានក្នុងទម្រង់ឌីជីថល រួមទាំងស្នាដៃដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ នៅកន្លែងណាក៏ដោយលើពិភពលោក។ កត្តាទីពីរគឺការបង្កើនសារៈសំខាន់សេដ្ឋកិច្ចអំពីចលនាទំនិញ និងសេវាកម្មដែលបានការពារដោយកម្មសិទ្ធិបញ្ញាក្នុងអាណាចក្រពាណិជ្ជកម្មអន្តរជាតិ ពាណិជ្ជកម្មក្នុងផលិតផលកម្មសិទ្ធិបញ្ញាបច្ចុប្បន្នគឺមានការរីកចំរើនក្នុង ពាណិជ្ជកម្មពិភពលោក។ កិច្ចព្រមព្រៀងTRIPS ដែលចែងលម្អិតអំពីបញ្ញត្តិក្នុងការអនុវត្តន៍សិទ្ធិ គឺជាភស្តុតាងគ្រប់គ្រាន់ពីទំនាក់ទំនងថ្មីរវាងកម្មសិទ្ធិបញ្ញា និងពាណិជ្ជកម្ម។ កថាខ័ណ្ឌខាងក្រោមពន្យល់ និងសង្ខេបអំពីបញ្ញត្តិការអនុវត្តន៍ច្បាប់មួយចំនួនដែលបានជួបប្រទះក្នុងច្បាប់ជាតិនាពេលបច្ចុប្បន្ន ដែលអាចត្រូវបានបែងចែកជាប្រភេទដូចខាងក្រោម៖ វិធានអភិរក្ស ឬវិធានការបណ្តោះអាសន្ន វិធានការស៊ីវិល វិធានការព្រហ្មទណ្ឌ វិធានការតាមមាត់ច្រកព្រំដែន និងវិធានការ សំណង និងទណ្ឌកម្មប្រឆាំងចំពោះឧបករណ៍បច្ចេកទេស។

**វិធានការអភិរក្ស ឬវិធានការបណ្តោះអាសន្ន** មានគោលបំណងពីរ៖ ទីមួយ រារាំងការរំលោភបំពានមិនឱ្យកើតឡើង ជាពិសេសរារាំងការឈានដល់ការរំលោភបំពានលើមុខទំនិញទៅក្នុងបណ្តាញពាណិជ្ជកម្ម រួមទាំងការហូរចូលទំនិញបន្ទាប់ពីការត្រួតពិនិត្យពន្ធគយ និងទីពីររក្សាភ័ស្តុតាងទាក់ទងផ្សេងៗដែលអាចចោទប្រកាន់ពីការរំលោភបំពានដោយខុសច្បាប់។ ដូចនេះ អាជ្ញធរតុលាការក្នុងប្រទេសមួយចំនួនអាចមានសម្ថកិច្ចចេញវិធានការបណ្តោះអាសន្នដោយមិនចាំបាច់ជូនដំណឹងមុនដល់អ្នករំលោភបំពាន។ ក្នុងន័យនេះ អ្នកបំពានដោយខុសច្បាប់គឺត្រូវបានរារាំងមិនឱ្យធ្វើបំលាស់ទីទំនិញរំលោភបំពានដែលបានសង្ស័យ។ វិធានការបណ្តោះអាសន្នទូទៅ គឺការឆែកឆេរទំនិញជនល្មើស និងរឹបអូសទំនិញរំលោភបំពាន ឧបករណ៍ប្រើប្រាស់

©WIPO/OMPI

ដើម្បីផលិតទំនិញល្មើស និង ឯកសារពាក់ព័ន្ធទាំងអស់ និងការថតចម្លងដ៏ទៃៗទៀតពីសកម្មភាពពាណិជ្ជកម្មដែលរំលោភបំពានដោយខុសច្បាប់។

**វិធានការរដ្ឋប្បវេណី** ទូទាត់សងម្ចាស់សិទ្ធិសម្រាប់ការធ្វើឲ្យខូចប្រយោជន៍ពាណិជកម្ម ដែលបានទទួលរង ដោយសារការរំលោភបំពាន ធម្មតាក្នុងទម្រង់ការខូចខាតប្រាក់កាក់ និង បង្កើតមានការញញើតដល់ការការរំលោភបំពានបន្តទៀត។ ជាញឹកញាប់ក្នុងទម្រង់ជាការបញ្ជារបស់តុលាការឱ្យបំផ្លាញទំនិញរំលោភបំពាន និងសម្ភារៈ និងប្រដាប់ប្រដាដែលបានប្រើប្រាស់សម្រាប់ផលិតទំនិញ នៅពេលដែលអាចមានការបន្តអំពើរំលោភបំពានតទៅទៀត តុលាការអាចនឹងចេញវិធានការបណ្ដោះអាសន្នប្រឆាំងនឹងអំពើនោះ ការខកខានបំពេញតាមវិធានការនោះនឹងជាកម្មវត្ថុដែលអ្នករំលោភ បពានទទួលនូវការផាកពិន័យ។

**វិធានការព្រហ្មទណ្ឌ** មានបំណងដាក់ទណ្ឌកម្មដល់បុគ្គលណាដែលលួចចម្លង សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលលក្ខណៈពាណិជ្ជកម្ម ដូចក្នុងករណីរដ្ឋប្បវេណី ដើម្បីបង្កាការរំលោភបំពានបន្តទៀត។ គោលបំណងនៃការដាក់ទណ្ឌកម្មគឺត្រូវបានធ្វើឡើងដោយការដាក់ឱ្យទទួលពិន័យធ្ងន់ធ្ងរ និងកាត់ទោសដាក់ពន្ធនាគារ ស្រប់តាមទម្ងន់ទោស ដែល អនុវត្តចំពោះ បទល្មើស ដែលទាក់ទងនឹងភាពធ្ងន់ធ្ងរ ជាពិសេសក្នុងករណីមិនរាងចាល។ គោលបំណងនៃការធ្វើរាងចាលគឺត្រូវបានធ្វើឡើងដោយការបញ្ជាឱ្យរឹបអូស ការរឹបអូស និងការបំផ្លាញទំនិញរំលោភបំពាន ដូចជាសម្ភារៈ និងប្រដាប់ប្រដាប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

©WIPO/OMPI

**វិធានការតាមមាត់ច្រកព្រំដែន** គឺជាខុសគ្នាពីវិធានការការអនុវត្តច្បាប់ដែលបានពិពណ៌នាកន្លងមក វិធានការនេះទាក់ទងនឹងសកម្មភាពធ្វើឡើងដោយអាជ្ញាធរគយជាជាងដោយអាជ្ញាធរតុលាការ។ វិធានការតាមមាត់ច្រកព្រំដែនអនុញ្ញាតឲ្យម្ចាស់សិទ្ធិស្នើទៅអាជ្ញាធរគយព្យួរទុកក្នុងការចរាចរណ៍នូវទំនិញដែលបានសង្ស័យពការរំលោភបំពានសិទ្ធិអ្នកនិពន្ធ។ គោលបំណងនៃការព្យួរទុកទៅក្នុងការចរាចណ៍គឺផ្តល់ឲ្យម្ចាស់សិទ្ធិនូវពេលវេលាសមស្របដល់ការចាត់និតិវិធីតុលាការប្រឆាំងនឹងអ្នករំលោភបំពានដែលបានសង្ស័យ គ្មានហានិភ័យនៃការដាក់ឱ្យចរាចរណទំនិញរំលោភបំពានទៅក្នុងទីផ្សារបន្ទាប់ការពិនិត្យគយ។ ជាទូទៅម្ចាស់សិទ្ធិត្រូវតែបង្ហាញអាជ្ញាធរគយថាមានភ័ស្តុតាងគ្រប់គ្រាន់អំពីការរំលោភបំពាន ត្រូវផ្តល់ឲ្យការពិពណ៌នាលម្អិតនៃទំនិញដូចនេះអាចធ្វើឱ្យងាយស្រួលក្នុងការស្គាល់ទំនិញ និងត្រូវផ្តល់ប្រាក់ធានាដើម្បីជួសជុលការខូចខាតដល់អ្នកនាំចូល ម្ចាស់ទំនិញ និងអាជ្ញាធរគយក្នុងមិនមានការរំលោភបំពាន។

ប្រភេទវិធានការអនុវត្តន៍ច្បាប់ចុងក្រោយ ដែលបានសម្រេចជាសារៈសំខាន់បំផុតក្នុងការប្រើប្រាស់ក្នុងបច្ចេកវិជ្ជាឌីជីថល រួមមាន វិធានការ ដំណោះស្រាយ និងទណ្ឌកម្មប្រឆាំងការរំលោភចំពោះមធ្យោបាយបច្ចេកទេស។ ក្នុងករណីមួយចំនួន មធ្យោបាយជាក់ស្តែងក្នុងការបង្ការការថតចម្លង ដែលគេហៅថា ប្រព័ន្ធការពារការថតចម្លងឬប្រព័ន្ធគ្រប់គ្រងការថតចម្លង ដែលមាន ឧបករណ៍បច្ចេកទេសដែលរារាំងការថតចម្លង ឬធ្វើឱ្យគុណភាពនៃការថតចម្លងអន់ ដែលធ្វើឱ្យមិនអាចប្រើប្រាស់បាន។ ឧបករណ៍បច្ចេកទេសក៏រារាំងការទទួលការបំប្លែងជាកម្មវិធីទូរទស្សន៍ផងដែរ លើកលែងជាមួយការប្រើប្រាស់ជាអក្សរកូដ។ ប៉ុន្តែជាបច្ចេកទេសអាចបង្កើតឧបករណ៍ដោយមធ្យោបាយប្រព័ន្ធកិច្ចការពារការថតចម្លងនិងប្រព័ន្ធការគ្រប់គ្រងការថតចម្លង ក៏ដូចជាប្រព័ន្ធបំលែងប្តូ។ ទ្រឹស្តីក្រោមវិធានការប្រឆាំងការរំលោភបំពានអំពីឧបករណ៍នេះគឺការផលិត ការនាំចូល និងការចែកចាយគួរត្រូវបានចាត់ទុកថារំលោភបំពានសិទ្ធិអ្នកនិពន្ធដែលត្រូវដាក់ទណ្ឌកម្មប្រហាក់ប្រហែលនឹងការប្រព្រឹត្តល្មើសដ៏ទៃៗទៀត។

©WIPO/OMPI

## កិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងសិទ្ធិអ្នកនិពន្ធ

សូមស្តាប់នូវវគ្គសម្លេងខាងក្រោម ដែលពិពណ៌នាអំពីកិច្ចព្រមព្រៀងអន្តរជាតិក្នុងវិស័យសិទ្ធិអ្នកនិពន្ធ។

សម្លេងវគ្គ ៦: តើអនុសញ្ញាអន្តរជាតិសំខាន់ ឬសន្ធិសញ្ញាសំខាន់ដែលគ្រប់គ្រងវិស័យសិទ្ធិអ្នកនិពន្ធមានអ្វីខ្លះ?

សន្ធិសញ្ញាដំបូងគឺអនុសញ្ញាទីក្រុងប៊ែនស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ។ អនុសញ្ញានេះ បង្កើតនៅឆ្នាំ១៨៨៦ ប៉ុន្តែបានកែជាច្រើនដង តួយ៉ាងប្រមាណក្នុងចន្លោះ ២០ ឆ្នាំ។ កំណែប្រែចុងក្រោយបំផុតបានចូលជាធរមានក្នុងទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៧១។

អនុសញ្ញាទីក្រុងប៊ែនទាក់ទងនឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធ។ វាផ្តោតជាមូលដ្ឋានដូចជាប្រព្រឹត្តិកម្មជាតិ មានន័យថាក្រោមច្បាប់ជាតិអ្នកមិនអាចប្រកាន់ប្រឆាំងនឹងស្នាដៃពីប្រទេសជាសមាជិកដ៏ទៃៗទៀតនៃអនុសញ្ញា។ វាផ្អែកលើស្តង់ដាកិច្ចការពារអប្បរមា ដែលត្រូវកំណត់ដោយច្បាប់ជាតិ ទោះបីច្បាប់ជាតិអាចថែងផ្សេងពីនេះ និងបង្កើតគោលការណ៍ដ៏ទៃទៀត។

បច្ចុប្បន្ន យើងមានកិច្ចព្រមព្រៀងTRIPS។ កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញានេះ គឺជាកិច្ចព្រមព្រៀងមួយនៃកិច្ចព្រមព្រៀងទាំងឡាយដែលផុសចេញពីកិច្ចប្រជុំ Uruguay ស្តីអំពីការចរចាពាណិជ្ជកម្ម និងត្រូវបានគ្រប់គ្រងដោយអង្គការពាណិជ្ជកម្មពិភពលោក។

កិច្ចព្រមព្រៀងTRIPSក្នុងចំណោមកិច្ចព្រមព្រៀងដ៏ទៃៗទៀតមានការយោងទៅបទប្បញ្ញត្តិជាសារធាតុនៃអនុសញ្ញាទីក្រុងប៊ែន ដែលមិនថែងពីសិទ្ធិសីលធម៌ដែលមិនត្រូវបានចាត់ទុកថាពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ ដើម្បីឱ្យមានអនុលោមភាពតាមកិច្ចព្រមព្រៀងTRIPS ប្រទេសទាំងឡាយ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងប៊ែនសម្រាប់ការចាប់ផ្តើមបន្ទាប់មកមានបទដ្ឋានបន្ថែមមួយចំនួននៃកិច្ចការពារដែលបានបង្ហាញដោយកិច្ចព្រមព្រៀងTRIPS ជាសំខាន់បំផុតចំពោះ ប្រភេទនៃការបង្កើតថ្មី (កម្មវិធីកុំព្យូទ័រ និងប្រព័ន្ធទិន្នន័យដើម) និងទម្រង់ថ្មីនៃអាជីវកម្ម (សិទ្ធិជួល)។

©WIPO/OMPI

ដូចនេះប្រទេសដែលចូលជាសមាជិក ឬឲ្យសច្ចាប័នកិច្ចព្រមព្រៀងTRIPSត្រូវតែអនុលោមធ្វើតាមអនុសញ្ញាតទីក្រុងប៉ែន (ទោះជា មាត្រា ៦ ស្ទួននៃអនុសញ្ញាទីក្រុងប៉ែន មិនចែងអំពីសិទ្ធិសីលធម៌ ដែលមិនទាក់ទងនឹងពាណិជ្ជកម្ម ដោយសិទ្ធិសីលធម៌ មិនមែនជាវត្ថុអាចលក់ដូរបាន) បន្ថែមពីនេះកិច្ចព្រមព្រៀងTRIPS ក៏មានចែងពីទិដ្ឋភាពនៃ សិទ្ធិអ្នកនិពន្ធទាក់ទងនឹងបច្ចេកវិជ្ជាថ្មី ។

©WIPO/OMPI

ពន្យល់ពីវគ្គសម្លេងដែលអ្នកបានស្តាប់ សន្និសីទការទូតដែលបានធ្វើឡើង ក្នុងខែធ្នូ ឆ្នាំ១៩៩៦ បានបង្កើតកិច្ចព្រមព្រៀងការពារសិទ្ធិអ្នកនិពន្ធអន្តរជាតិថ្មី ដូចជា សន្និសញ្ញាWIPO ស្តីពីសិទ្ធិអ្នកនិពន្ធ (WCT)។ សន្និសញ្ញានេះ ឆ្លើយតបចំពោះតម្រូវការការពារស្នាដៃពេលផ្ទេរជាលក្ខណៈឌីជីថល រួមទាំងតាមអ៊ីនធើណែត។ កម្មវត្ថុដែលត្រូវបានការពារតាមរយៈសិទ្ធិអ្នកនិពន្ធដោយ WCT រួមមានកម្មវិធីកុំព្យូទ័រ ទោះក្នុង របៀប ឬទម្រង់ណាក៏ដោយ និងការចងក្រងទិន្នន័យ ឬទិន្នន័យដទៃៗទៀត (ប្រព័ន្ធទិន្នន័យ) ក្នុងទម្រង់ ណាមួយ ដោយហេតុផលនៃការជ្រើសរើស ឬរៀបចំមាតិកាបង្កើតបានជា ការបង្កើតដោយបញ្ញា។ សិទ្ធិអ្នកនិពន្ធរួមមាន សិទ្ធិចែកចាយ សិទ្ធិជួល និងសិទ្ធិផ្សព្វផ្សាយជាសាធារណៈ ហើយបញ្ជាក់ច្បាស់ថាសិទ្ធិផ្សព្វផ្សាយជាសាធារណៈគ្របដណ្តប់ការផ្ទេរស្នាដៃតាមរយៈបណ្តាយឌីជីថលដូចជាអ៊ីនធឺណែត។ វាក៏បានចែងផងដែរថាសិទ្ធិផលិតឡើងវិញដែលបានកំណត់ក្នុងអនុសញ្ញាទីក្រុងប៊ែន ត្រូវបានអនុវត្តយ៉ាងពេញលេញក្នុងបរិយាកាសឌីជីថល។ ហេតុនេះការរក្សាទុកស្នាដៃក្នុងទម្រង់ឌីជីថលក្នុងឧបករណ៍អេឡិចត្រូនិច (ឧទាហរណ៍ ការរក្សារទុកក្នុងអង្គរចងចាំរបស់កុំព្យូទ័រ) គួរចាត់ទុកជាការផលិតឡើងវិញ ។ សិទ្ធិទាំងនេះ ជាធម្មតា គឺជាវត្ថុនៃការកម្រិត និងការលើកលែងមួយចំនួន។

---

សម្គាល់: សន្និសញ្ញាដទៃទៀត ដែលបានធ្វើឡើងក្នុងសន្និសីទការទូតដូចគ្នានោះ ក៏បានបង្កើតសន្និសញ្ញា WIPO ស្តីពីការសម្តែង និងហ្វូណូក្រាម ។ សន្និសញ្ញានេះគឺបានពិភាក្សាក្នុងមេរៀនសិទ្ធិប្រហាក់ប្រហែល។

©WIPO/OMPI

## សំនួរវាយតម្លៃខ្លួនឯង (SAQ)

SAQ 6: តើអ្វីដែលបានគ្របដណ្តប់ក្រោម WCT?

សរសេរចំលើយរបស់អ្នកទីនេះ

ចុចទីនេះសម្រាប់ចំលើយ

©WIPO/OMPI

**SAQ 5 ចំលើយ:**

WCT ត្រូវបានបង្កើតឡើងព្រោះតែ ប្រទេសហត្ថលេខីបានទទួលស្គាល់ពីតម្រូវការដើម្បីផ្តល់ឲ្យមានដំណោះស្រាយគ្រប់គ្រាន់ចំពោះបញ្ហាដែលកើតឡើងពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកទេស។ នេះសំដៅជាពិសេសចំពោះតម្រូវការនៃកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈដែលបានផ្ទេរតាមរយៈអ៊ីនធឺណែត។ ជាពិសេសស្នាដៃដែលបានលើកឡើងដោយ WCT រួមមានកម្មវិធីកុំព្យូទ័រ និងប្រព័ន្ធទិន្នន័យ។ WCT ពង្រីកព្រំដែនកិច្ចការពារសិទ្ធអ្នកនិពន្ធចំពោះការសម្តែងគំនិត មិនមែនគ្រាន់តែជាការគិតនោះទេ និតិវិធី របៀបប្រតិបត្តិការ ឬគំនិតគណិតវិទ្យា ជាដើម។ ស្នាដៃរបស់អ្នកនិពន្ធបានគ្របដណ្តប់ដោយ WCT ក៏មានផងដែរនូវសិទ្ធិចែកចាយ សិទ្ធិជួល និងសិទ្ធិផ្សព្វផ្សាយជាសាធារណៈ។

©WIPO/OMPI

ជាចុងក្រោយ សេចក្តីសន្និដ្ឋាននៃមេរៀននេះក្នុងសិទ្ធិអ្នកនិពន្ធ ចូរផ្តោតពីសារៈសំខាន់អំពីច្បាប់សិទ្ធិអ្នកនិពន្ធក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

## តើមានគុណប្រយោជន៍អ្វីសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ពីកិច្ចការពារសិទ្ធិអ្នកនិពន្ធ?

តើគុណប្រយោជន៍ពីកិច្ចការពារសិទ្ធិអ្នកនិពន្ធសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍មានអ្វីខ្លះ?

មានគុណប្រយោជន៍វប្បធម៌និងគុណប្រយោជន៍សេដ្ឋកិច្ច។ ជាកាពិតយើងគួរតែមិនគួរបំភ្លេចថាសិទ្ធិអ្នកនិពន្ធ ក៏ពាក់ព័ន្ធនឹងវប្បធម៌ផងដែរ។ ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់មានសហគមសិល្បៈភ្លាំងខ្លាំបំផុត។ មិនមានមនុស្សលើផែនដី ដែលមិនមានការច្នៃប្រឌិតនោះទេ និងប្រាកដណាស់ប្រសិនបើមិនមានកិច្ចការពារសិទ្ធិអ្នកនិពន្ធ សហគមន៍សិល្បៈនឹងត្រូវបានគេបោកបញ្ឆោត និងរារាំងពីទទួលកម្រៃជាប្រាក់ពីកិច្ចខំប្រឹងប្រែងរបស់ពួកគេ។ សព្វថ្ងៃនេះស្នាដៃអក្សរសាស្ត្រ និងសិល្បៈបានក្លាយជាទស្សនៈយ៉ាងទូលាយ រួមទាំងជាផ្នែកនៃវប្បធម៌ សហគមន៍សិល្បៈ ឧស្សាហកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យា ឬឧស្សាហកម្មកម្មវិធីកុំព្យូទ័រផងដែរ។

ចំនួនប្រាក់ជាច្រើន ប្រហែលត្រូវបាននិយោគក្នុងការបង្កើតកម្មវិធីកុំព្យូទ័រមួយ ឬខ្សែភាពយន្ត ឬ កម្មវិធីទូរទស្សន៍មួយ។ ប៉ុន្តែប្រសិនបើមានការថតចម្លងគឺចេញលើទីផ្សា មនុស្សគ្រប់គ្នាគឺត្រូវបានអនុញ្ញាឱ្យថតចម្លងវា ពេលនោះនឹងបាត់បង់ចំនូលវសក្តានុពល និងមិនមានការលើកទឹកចិត្តចំពោះការច្នៃប្រឌិត ឬជួយជ្រោមជ្រែងវិនិយោគតទៅទៀត។ ហេតុនេះ នឹងគ្មានការជម្រុញឱ្យមានការច្នៃប្រឌិតដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ វប្បធម៌ជាតិយ។ នោះគឺជាទិដ្ឋភាពមួយ។ ឆ្លើយតបបញ្ហានេះ គួរតែអាចនិយាយថាស្នាដៃក្នុងស្រុកគួរត្រូវបានការពារ ប៉ុន្តែគួរតែគ្មានកិច្ចការពារចំពោះស្នាដៃបរទេស ពីព្រោះអាចមានលំហូរប្រាក់ចេញពីប្រទេសប្រទេសកំពុងអភិវឌ្ឍន៍អាចនឹងជួបនឹងផលអាក្រក់។

ប៉ុន្តែ នេះជាទិដ្ឋភាពខ្លីមួយប៉ុណ្ណោះ។ មានការសំអាងដ៏រឹងមួយចំនួនថាអាចលើកឡើងក្នុងការគាំទ្រកិច្ចការពារស្នាដៃអន្តរជាតិ។

ដំបូង ប្រសិនបើកិច្ចការពារគឺត្រូវបានកំណត់ត្រឹមតែចំពោះស្នាដៃជាតិ ស្នាដៃបរទេស នឹងត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងទីផ្សាក្នុងស្រុកដោយគ្មានកំណត់តម្លៃសិទ្ធិអ្នកនិពន្ធណាមួយ។ ស្នាដៃទាំងនេះត្រូវបានលក់ក្នុងតម្លៃទាប។ ពិតណាស់ អ្នកប្រើប្រាស់ប្រហែលជាទទួលបានផល

©WIPO/OMPI

ប្រយោជន៍ពីតម្លៃទាបដូចនោះ។ ប៉ុន្តែការអនុវត្តន៍នេះអាចនឹងមាឥទ្ធិពលខូចប្រយោជន៍ដល់ការលក់ផលិតផលដែលបានបង្កើតក្នុងស្រុក ណាមួយ ដែលមានប្រកួតជាមួយស្នាដៃបរទេសដើមដែលបានចែកចាយក្នុងតម្លៃទាក់ទាញ។ លទ្ធផលគ្រោះថ្នាក់គឺថាអ្នកប្រើប្រាស់ប្រហែលជាបែរខ្នងដាក់ផលិតផលជាតិ និងងាកទៅទិញផលិតផលបរទេសដែលមិនសូវថ្លៃ។ វប្បធម៌ជាតិ ដូចជាតន្ត្រី ឬសៀវភៅ ឬឧស្សាហកម្មដ៏ទៃៗទៀត អាចមានផលប៉ះពាល់ ។

ទីពីរ មិនអាចបញ្ជាក់គ្រប់គ្រាន់នូវផលចំណេញដែលសិល្បករក្នុងស្រុង និងអ្នកច្នៃប្រឌិតទោះជាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឬក៏មិនអភិវឌ្ឍន៍ ប្រហែលជាមកពីកិច្ចការពារស្នាដៃរបស់ពួកគេនៅបរទេ។ ទីផ្សាក្នុងស្រុកប្រហែលជាអាចមានកម្រិត និងមានតម្រូវការ ទាញចំណូលពីផលិតផលវប្បធម៌ដែលត្រូវបាននាំចេញ និងលក់នៅខាងក្រៅ។អរគុណដល់មធ្យោបាយទំនាក់ទំនងទំនើបបច្ចុប្បន្ន ស្នាដៃត្រូវបានគេស្តាប់ ឬអាន ឬឃើញ មិនត្រឹមតែក្នុងសហាគមន៍ក្នុងស្រុក ឬប្រទេស ដែលពួកគេបានបង្កើតនោះទេ ប៉ុន្តែក៏បានផងដែរនៅតំបន់ឆ្ងាយៗ។ ក្នុងករណីមួយចំនួន ប្រាក់ចំណូលច្រើនបំផុតដែលបានបង្កើតពីអាជីវកម្មស្នាដៃមួយក្នុងដែនដីបរទេស ផ្តល់ចំណូលយ៉ាងច្រើនលើសពីចំណូលដែលទទួលបានពីអាជីវកម្មក្នុងស្រុក។ ករណីទាំងនេះអាចត្រូវបានគេសង្កេតឃើញច្រើនក្នុងវិស័យតន្ត្រី កម្មវិធីទូរទស្សន៍ សូវវែ ខ្សែភាពយន្ត សៀវភៅ។ល។ កិច្ចការពារក្រៅប្រទេស ក្នុងទីផ្សាបរទេសគឺពិតជាំមានសារៈសំខាន់ណាស់ចំពោះអ្នកនិពន្ធ និងអ្នកបង្កើត។ ត្រូវយល់ថាសិល្បករម្នាក់ ឬអ្នក អង្កើតម្នាក់មកពីប្រទេសណាមួយ នឹងមិនទទួលបានកិច្ចការពារក្រៅប្រទេស ប្រសិនបើអ្នកនិពន្ធ និងសិល្បកបរទេស មិន ទទួលបាននូវកិច្ចការពារក្នុងប្រទេសរបស់ខ្លួន។

©WIPO/OMPI

## សង្ខេប

មេរៀននេះ បាននិយាយពីរចនាសម្ព័ន្ធទូទៅនៃច្បាប់សិទ្ធិអ្នកនិពន្ធ និងបានផ្តល់ឲ្យនូវទស្សនៈអពី:

(1). ស្នាដៃអក្សរសាស្រ្ត និងសិល្បៈដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ

(2). សិទ្ធិដែលទទួលបានពីម្ចាស់សិទ្ធិអ្នកនិពន្ធ

(3). ភាពជាម្ចាស់ និងការផ្ទេរសិទ្ធិអ្នកនិពន្ធ

(4). រយៈពេលនៃកិច្ចការពារ

(5). ការដាក់កំហិតលើសិទ្ធិ

(6). ការអនុវត្តន៍ច្បាប់អំពីសិទ្ធិ និង

(7). កិច្ចព្រមព្រៀងទាក់ទងទៅនឹងសិទ្ធិអ្នកនិពន្ធ

អនុសញ្ញាទីក្រុងប៊ែនបានរាយបញ្ជី 'ស្នាដៃអក្សរសាស្រ្ត និងសិល្បៈ' ដូច្នោះយ៉ាងទូលំទូលាយ "រាល់ផលិតកម្មក្នុងវិស័យអក្សរសាស្រ្ត វិទ្យាសាស្រ្ត និងសិល្បៈ អ្វីក៏ដោយប្រហែលជារបៀប ឬទម្រង់ពីវិញ្ញាត្តិ" ត្រូវបានរួមបញ្ចូល។ បានគ្របដណ្តប់ក្រោមលក្ខខ័ណ្ឌដ៏ទូលាយនេះគឺរាល់ស្នាដៃដើមនៃភាពជាអ្នកនិពន្ធ ធ្វេសប្រហែសនឹងទទួលបានអំពីអក្សរសាស្រ្ត ឬសិល្បៈ។

ម្ចាស់សិទ្ធិអ្នកនិពន្ធក្នុងស្នាដៃ ដែលបានការពារមួយប្រហែលប្រើប្រាស់ស្នាដៃដូចដែលគាត់ចង់បាន ហើយប្រហែលជារារាំងអ្នកដ៏ទៃទៀតពីការប្រើប្រាស់ស្នាដៃដោយគ្មានការអនុញ្ញាត្តិពីគាត់។ ដូច្នេះ ចាប់តាំងពីម្ចាស់ប្រហែលជាមិនរាប់បញ្ចូលអ្នកដ៏ទៃទៀតពីសកម្មភាពប្រឆាំងនឹងផលប្រយោជន៍របស់ម្ចាស់ ដែលសិទ្ធិទាំងនេះគឺបានសំដៅទៅជា "សិទ្ធិផ្តាច់មុខ"។ មានសិទ្ធិពីប្រភេទដ៏ទៃទៀតបានគ្របដណ្តប់ក្រោមសិទ្ធិអ្នកនិពន្ធដូចជា សិទ្ធិបិតិកភ័ណ្ឌ និងសិទ្ធិសីលធម៌។ នៅក្នុងការការពារនៃ*សិទ្ធិបិតិកភ័ណ្ឌ*គឺជាសិទ្ធិជាច្រើនទាំងនេះ ហើយការដាក់កំហិតដែលត្រូវអនុវត្តបាន ណាមួយប្រហែលជាត្រូវបានផ្ទេរសិទ្ធិពីម្ចាស់ដើម។ *សិទ្ធិសីលធម៌* នឹងតែងតែនៅជាមួយម្ចាស់ដើមសំខាន់ទោះជាសិទ្ធិបិតិកភ័ណ្ឌត្រូវបានផ្ទេរក៏ដោយ។

បន្ថែមពីនេះប្រភេទស្នាដៃដែលបានបញ្ជាក់ខាងលើ ប្រភេទថ្មីចំពោះស្នាដៃមួយត្រូវបានគ្របដណ្តប់ក្រោមសិទ្ធិអ្នកនិពន្ធដែលបានផុសចេញ។ នេះគឺជាផលិតកម្មពហុរូបអារក្ស និងទោះជាមិនមាននិយមន័យស្របច្បាប់ ក៏មានមតិទូទៅថាការរួមបញ្ចូលគ្នានៃសម្លេង អត្ថបទ និងរូបភាពក្នុងទម្រង់ឌីជីថល ណាមួយគឺបានធ្វើឲ្យអាចដំណើរការដោយកម្មវិធីកុំព្យូទ័រគឺត្រូវបាន

©WIPO/OMPI

ពិចារណាថាជាវិញ្ញាត្តិដើមនៃភាពជាម្ចាស់ ហើយហេតុនេះ គឺត្រូវបានគ្របដណ្តប់ក្រោមការការពារសិទ្ធិអ្នកនិពន្ធ។

**អត្ថបទច្បាប់:**

អនុសញ្ញាទីក្រុងប៊ែន សម្រាប់ការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ

កិច្ចព្រមព្រៀងទ្រីប TRIPS

សន្ធិសញ្ញាការសម្តែង និងហ្វូណូក្រាម WIPO (WPPT)

សិន្ធិសញ្ញាសិទ្ធិអ្នកនិពន្ធ WIPO (WCT)

©WIPO/OMPI